


ព្រះ
វិន័យបិដក ភាសាខ្មែរ
និង
សេចក្តីប្រៀបធៀបភាសាខ្មែរ
វិនយបិដក ចុល្លវគ្គ
ភាគទី
១១

សង្ឃភេទក្ខន្ធកៈ វត្តក្ខន្ធកៈ

ភាតិមោក្ខដ្ឋបនក្ខន្ធកៈ ភិក្ខុនីខន្ធកៈ

បញ្ចសតិកក្ខន្ធកៈ និង សត្តសតិកក្ខន្ធកៈ



លើកទី ២

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៥០១

តតិយោ ភាគោ

សង្ឃភេទក្ខន្ធកំ

[១] តេន សមយេន ពុទ្ធោ ភគវា អនុបិយាយំ វិហរតិ អនុបិយំ នាម មល្លានំ និគមោ ។ តេន ខោ បន សមយេន អភិញ្ញាតា អភិញ្ញាតា សក្យកុមារា ភគវន្តំ បញ្ចដិតំ អនុប្បព្ពជន្តិ ។

[២] តេន ខោ បន សមយេន មហានាមោ ច សក្កោ អនុរុទ្ធោ ច សក្កោ ទ្វេ ភាតុកា ហោន្តិ ។ អនុរុទ្ធោ សក្កោ សុខុមាលោ ហោតិ ។ តស្ស តយោ បាសាទា ហោន្តិ ឧក្កោ ហេមន្តិកោ ឧក្កោ តេម្ហិកោ ឧក្កោ វស្សិកោ ។ សោ វស្សិកេ បាសាទេ បវ្ហារេ មាសេ និប្បុរិសេហិ តុរិយេហិ បរិចារិយមានោ ន ហេដ្ឋា បាសាទា[1] ឱរោហតិ ។ អថ ខោ មហានាមស្ស សក្កស្ស

---

១ ម. ហេដ្ឋាបាសាទំ ។

ឥតិយភាគ

សង្ឃភេទក្ខន្ធកៈ

(១) សម័យនោះ ព្រះពុទ្ធ មានព្រះភាគ គង់នៅក្នុងនិគម ឈ្មោះអនុបិយា ជានិគមរបស់មល្លក្សត្រ ទៀបព្រៃអនុបិយា ។ កាលសម័យ នោះឯង ពួកសក្យកុមារ សុទ្ធតែជាអ្នកមាននាមល្បីល្បាញ ចេញបួស តាមព្រះមានព្រះភាគ ដែលទ្រង់ព្រះផ្នួសហើយ ។

(២) សម័យនោះ មានសក្យៈជាបង្គំបួន ២ អង្គ ឈ្មោះមហានាម-សក្កៈ ១ ឈ្មោះអនុរុទ្ធសក្កៈ ១ ។ ឯអនុរុទ្ធសក្កៈជាស្តេចសុទ្ធមាលជាតិ[1] ។ អនុរុទ្ធសក្កៈនោះ មានប្រាសាទ ៣ ខ្នង ប្រាសាទមួយសម្រាប់រដូវរងា ប្រាសាទមួយសម្រាប់រដូវក្តៅ ប្រាសាទមួយសម្រាប់រដូវភ្លៀង ។ អនុរុទ្ធ-សក្កៈនោះ (គង់នៅ) លើប្រាសាទសម្រាប់រដូវភ្លៀងអស់បួនខែ មាន តន្ត្រីនៅចាំគាល់បម្រើ មិនមានមនុស្សប្រុស (នៅលាយ) មិនដែល យាងចុះអំពីប្រាសាទមកខាងក្រោមឡើយ ។ គ្រានោះឯង មហានាមសក្កៈ

---

១ ជាក្សត្រដែលបានសេចក្តីសុខ មិនដែលបានសេចក្តីលំបាកដោយខ្សែរំងាំងកំណើតថ្ងៃជាដើម។

ឯតទវោសិ ឯតរហិ ខោ អភិញ្ញាតា អភិញ្ញាតា សក្យកុមារា ភគវន្តំ បព្ពជិតំ អនុបព្ពជន្តិ អម្ហាកញ្ច បន[1] កុលា ឧត្តិ្តោចិ អគារស្មា អនគារិយំ បព្ពជិតោ យន្នូនាហំ ឯ បព្ពជេយ្យំ អនុរុទ្ធោ ឯតំ ។ អថខោ មហានាមោ សក្កោ យេន អនុរុទ្ធោ សក្កោ តេនុបសង្កមិ ឧបសង្កមិត្វា អនុរុទ្ធំ សក្កំ ឯតទវោច ឯតរហិ តាត អនុរុទ្ធ អភិញ្ញាតា អភិញ្ញាតា សក្យកុមារា ភគវន្តំ បព្ពជិតំ អនុបព្ពជន្តិ អម្ហាកញ្ច បន កុលា ឧត្តិ្តោចិ អគារស្មា អនគារិយំ បព្ពជិតោ តេនហិ តំ ឯ បព្ពជ អហំ ឯ បព្ពជិស្សាមីតិ ។ អហំ ខោ សុខុមាលោ ជាហំ សក្កោមិ អគារស្មា អនគារិយំ បព្ពជិតុំ តំ បព្ពជាហីតិ ។ ឯវំ ខោ តេ តាត អនុរុទ្ធ ឃរាវាសតន្តំ អនុសាសិស្សាមិ បឋមំ ខេត្តំ កសាបេតព្ពំ កសាបេត្វា វប្បាបេតព្ពំ វប្បាបេត្វា ឧទកំ អតិនេតព្ពំ ឧទកំ អតិនេត្វា ឧទកំ និន្នេតព្ពំ ឧទកំ និន្នេត្វា និន្នាបេតព្ពំ[2]

---

๑ ឧ. ម. ឃោគ្ឃកេសុ បនសព្ពោ ន ទិស្សតិ ។ ๒ ឧ. និន្នាបេតព្ពំ ។

មានសេចក្តីត្រិះរិះដូច្នេះថា ឥឡូវនេះពួកសក្យកុមារសុទ្ធតែជាអ្នកមាននាម
ល្បីល្បាញ ចានចេញបួសតាមព្រះមានព្រះភាគ ដែលទ្រង់ព្រះផ្នួស
ហើយ ចំណែកខាងត្រកូលរបស់យើងគ្មាននរណាមួយ ចេញចាកផ្ទះទៅ
បួសក្នុងសាសនាសោះ បើដូច្នោះគួរតែអាត្មាអញឬអនុរុទ្ធបួសកុំខានចុះ ។
ទើបមហានាមសក្កៈចូលទៅរកអនុរុទ្ធសក្កៈ លុះចូលទៅដល់ហើយ ចាន
និយាយរឿងនុ៎ះចំពោះអនុរុទ្ធសក្កៈថា ម្នាលអនុរុទ្ធ ជាអនុជ ឥឡូវនេះ ពួក
សក្យកុមារ សុទ្ធតែជាអ្នកមាននាមល្បីល្បាញ ចានចេញបួសតាមព្រះ
មានព្រះភាគ ដែលទ្រង់ព្រះផ្នួសហើយ ចំណែកខាងត្រកូលរបស់យើង
គ្មាននរណាមួយ ចេញចាកផ្ទះទៅបួសក្នុងសាសនាសោះ បើដូច្នោះចូរឯង
បួស ឬអញនឹងបួសក៏ចាន ។ អនុរុទ្ធឆ្លើយថា ខ្ញុំជាមនុស្សស្រុកមាលជាតិ
ខ្ញុំមិនអាចនឹងចេញចាកផ្ទះ ទៅបួសក្នុងសាសនាចានទេ សូមទ្រង់ស្តេច
បួសចុះ ។ មហានាមសក្កៈនិយាយថា ម្នាលអនុរុទ្ធ ជាអនុជ ចូរឯងមក
អាយ បងនឹងពន្យល់ប្រយោជន៍របស់យ៉ាងណាសដល់ឯងថា ការធ្វើស្រែនោះ
មុនដំបូងត្រូវភ្ជួរ ភ្ជួរចប់ហើយ ត្រូវព្រោះ ព្រោះចប់ហើយ ត្រូវបញ្ចូលទឹក
បញ្ចូលទឹកចប់ហើយ ត្រូវបញ្ចេញទឹក បញ្ចេញទឹកចប់ហើយ ត្រូវជំរះស្មៅ

ฉนฺทาเปตฺวา ฉวาเปตพฺพํ ฉวาเปตฺวา ขญฺหาเปตพฺพํ ขญฺหาเปตฺวา[๑] ปุญฺชํ กาเรตพฺพํ ปุญฺชํ กาเรตฺวา มญฺจาเปตพฺพํ มญฺจเปตฺวา ปลาลาฉนฺทเก ขุทฺทเกตพฺพานิ ปลาลาฉนฺทเก ขุทฺทเกตฺวา กุสิเก ขุทฺทเกตพฺพา กุสิเกหิ ขุทฺทเกตฺวา ฑิณฺฑุภาเปตพฺพํ ฑิณฺฑุภาเปตฺวา[๒] อตฺถรเกตพฺพํ อตฺถรเกตฺวา อายตเมว วสฺสิ วิหาเรว กาตพฺพํ อายตเมว วสฺสิ วิหาเรว กาตพฺพนฺติ ฯ ๘ กมฺมา ฑียนฺติ ๘ กมฺมานิ อตฺถิ ปญฺญายติ กตา กมฺมา ฑียิสฺสนฺติ กตา กมฺมานิ อตฺถิ ปญฺญายิสฺสติ กตา มยิ อเปฺปสกฺกา ปญฺหา กามกุณฺฑเก สมปฺปิตา สมฺปนฺนีกฺขตา ปริจริสฺสนฺติ ฯ ๘ หิ ตาต อนุรุทฺธ กมฺมา ฑียนฺติ ๘ กมฺมานิ อตฺถิ ปญฺญายติ อกฺกีณา[๓] กเมฺม มาตาปิตเรหิ[๔] จ ปิตามเหหิ จ กาลกตานิ ฯ เตสเมว หิ ภูญฺชิตพฺพา ยาวชีวมฺปิ ทุปชฺชาปิ หิ อหุ อการสฺสา อนาจารา ปฏิวิสฺสกีนนฺติ ฯ

---

๑ ฉ. ขญฺหาเปตฺวา ฯ ๒ ฉ. ม. ขุปาเปตพฺพ ขุปาเปตฺวา ฯ ๓ ฉ. อกฺกีณเยว ฯ ๔ ฉ. ม. ปิตเรหิ ฯ

ដំរះស្មៅរួចហើយ ត្រូវប្រួតស្រូវ ប្រួតស្រូវហើយ ត្រូវចងកណ្តាប់ ចងជាកណ្តាប់ហើយ ត្រូវធ្វើឲ្យជាគំនរ ធ្វើឲ្យជាគំនរហើយ ត្រូវបោកឬបញ្ហាន់ បញ្ហាន់ហើយ ត្រូវដង្ហុះយកចំបើង ដង្ហុះយកចំបើងហើយ ត្រូវដង្ហុះយកកំទេចចេញ ដង្ហុះយកកំទេចចេញហើយ ត្រូវរោយ រោយហើយ ត្រូវដង្ហែនយកមកទុក ដង្ហែនយកមកទុកហើយ ត្រូវចាប់ធ្វើតែយ៉ាងនេះតទៅទៀត រាល់ៗឆ្នាំ ត្រូវចាប់ធ្វើ (សាពីដើម) តាមទំនងនេះទៀត តែរាល់ ៗ ឆ្នាំ ។

អនុរុទ្ធសក្កៈនិយាយថា ការងារមិនចេះអស់ទេ ទីបំផុតនៃការងារមិនប្រាកដទេ កាលណានឹងអស់ការងារ កាលណានឹងប្រាកដថាផុតការងារបាន កាលណាយើងនឹងថយខ្លួនខ្លាយឆ្អែតឆ្អន់ នឹងស្កប់ស្កល់បម្រើដោយតាមគុណ ៥ ។ ម្នាលអនុរុទ្ធ ជាអនុជ ការងារមិនចេះអស់ទេ ទីបំផុតការងារក៏មិនប្រាកដ មាតាបិតាក្តី ជីតាក្តី ធ្វើមរណភាព(ទៅអស់) ឯការងារមិនចេះអស់ទេ ។ បើដូច្នោះ អនុជឯង ចូរជ្រាបអំពីប្រយោជន៍របស់ឃរាវាសចុះ បងមុខជានឹងចេញចាកផ្ទះ ទៅបួសក្នុងសាសនា (មិនខាន) ។

(៣) អថខោ អនុរុទ្ធោ សក្កោ យេន មាតា តេ-
នុបសង្កមិ ឧបសង្កមិត្វា មាតរំ ឯតទវោច ឥច្ឆាមហំ
អម្ម អគារស្មា អនគារិយំ បព្ពជិតុំ អនុជានាហិ មំ
អម្ម[1] អគារស្មា អនគារិយំ បព្ពជ្ជាយាតិ ។ ឯវំ វុត្តេ
អនុរុទ្ធស្ស សក្កស្ស មាតា អនុរុទ្ធំ សក្កំ ឯតទវោច
តុម្ហេ ខោ មេ តាត អនុរុទ្ធេ បុត្តា បិយា មនាបា
អម្ពដកូលា មរណេនបិ វោ អកាមកា វិនា ភវិស្សាមិ
កិំ បនាហំ តុម្ហេ ជីវន្តេ អនុជានិស្សាមិ អគារស្មា
អនគារិយំ បព្ពជ្ជាយាតិ ។ ទុតិយម្បិ ខោ ។ បេ ។
តតិយម្បិ ខោ អនុរុទ្ធោ សក្កោ មាតរំ ឯតទវោច
ឥច្ឆាមហំ អម្ម អគារស្មា អនគារិយំ បព្ពជិតុំ អនុជា-
នាហិ មំ អម្ម អគារស្មា អនគារិយំ បព្ពជ្ជាយាតិ[2] ។

(៤) តេន ខោ បន សមយេន ភទ្ទិយោ
សក្យរាជា សក្យានំ រជ្ជំ ការេតិ ។ សោ
ច[3] អនុរុទ្ធស្ស សក្កស្ស សហាយោ ហោតិ ។

---

១ ឧ. ម. ចោត្តកេសុ អម្មាតិ ន ទិស្សតិ ។ ២ ឥមេ បរំ ឯវំ វុត្តេ អនុរុទ្ធស្ស សក្កស្ស
មាតា ឯវមាហ ។ សចេ តាត អនុរុទ្ធ ភទ្ទិយោ សក្យមហារាជា សក្យានំ រជ្ជំ ការេតិ
អគារស្មា អនគារិយំ បព្ពជតិ ។ ឯវំ បព្ពជាហីតិ ឥមេ ឆយិ មរម្មចោត្តកេ ទិស្សន្តិ ។
៣ ឧ. ម. ចោត្តកេសុ សោ បសទ្ធោ ន ទិស្សតិ ។

(៣) ក្នុងគ្រានោះ អនុរុទ្ធសក្កៈបួលទៅរកព្រះមាតា លុះបួលទៅដល់ហើយ ក៏និយាយនឹងព្រះមាតាយ៉ាងនេះថា បពិត្រព្រះមាតា ខ្ញុំចង់ចេញចាកផ្ទះទៅបួសក្នុងសាសនា បពិត្រព្រះមាតា សូមព្រះមាតាអនុញ្ញាតឲ្យខ្ញុំចេញចាកផ្ទះទៅបួស ក្នុងសាសនា ។ កាលបើអនុរុទ្ធសក្កៈនិយាយយ៉ាងនេះហើយ ព្រះមាតានៃអនុរុទ្ធសក្កៈនិយាយយ៉ាងនេះថា ម្នាលអនុរុទ្ធកូន អ្នកជាបុត្រប្រុសតាំងពីរបស់យើង រមែងជាទីស្រឡាញ់ពេញចិត្ត ឥតមានស្អប់ខ្ពើមទេ សូម្បីដល់មរណកាល យើងក៏ពុំចង់ព្រាត់ប្រាសនឹងអ្នកឡើយ កាលបើអ្នករស់នៅ ។ ឡើយ យើងធ្វើម្តេចនឹងយល់ព្រមឲ្យអ្នកចេញចាកផ្ទះទៅបួសក្នុងសាសនាបាន ។ អនុរុទ្ធសក្កៈនិយាយនឹងព្រះមាតាយ៉ាងនេះអស់វារៈពីរដងផង ។ បេ ។ អស់វារៈបីដងផងថា បពិត្រព្រះមាតា ខ្ញុំចង់ចេញចាកផ្ទះទៅបួសក្នុងសាសនា បពិត្រព្រះមាតា សូមព្រះមាតាអនុញ្ញាត ឲ្យខ្ញុំចេញចាកផ្ទះទៅបួសក្នុងសាសនា ។

(៤) សម័យនោះឯង កុដិយសក្យរាជសោយរាជ្យជាស្តេចរបស់សក្យៈតាំងពីរឡាយ ។ ឯកុដិយសក្យរាជនោះត្រូវជាសំឡាញ់នឹងអនុរុទ្ធសក្កៈ ។

អថខោ អនុរុទ្ធស្ស សក្កស្ស មាតា អយំ ខោ កច្ចិយោ សក្យរាជា សក្យានំ រដ្ឋំ ការេតិ អនុរុទ្ធស្ស សក្កស្ស សហាយោ សោ ន ឧស្សហតិ អគារស្មា អនគារិយំ បព្ពជិតុន្តិ អនុរុទ្ធំ សក្កំ ឯតទវោច សចេ តាត អនុរុទ្ធ កច្ចិយោ សក្យរាជា អគារស្មា អនគារិយំ បព្ពជតិ ឃំ តុម្ហ៎ិ បព្ពជាហីតិ ។ អថខោ អនុរុទ្ធោ សក្កោ យេន កច្ចិយោ សក្យរាជា តេនុបសង្កមិ ឧបសង្កមិត្វា កច្ចិយំ សក្យរាជានំ ឯតទវោច មម ខោ សម្ម បព្ពជ្ជា តវ បដិពន្ធាតិ ។ សចេ តេ សម្ម បព្ពជ្ជា មម បដិពន្ធា ឃ[1] អម្ហដិពន្ធា ឃ សា ហោតុ អហំ តយោ យថាសុខំ បព្ពជាមីតិ ។ ឯវំ សម្ម ឧភោ អគារស្មា អនគារិយំ បព្ពជិស្សាមាតិ ។ ជាឃំ សម្ម សក្កោមិ អគារស្មា អនគារិយំ បព្ពជិតុំ យំ តេ សក្កា អញ្ញំ មយា ការេតុំ តាឃំ ការិស្សាមិ តុំ បព្ពជាហីតិ ។ មាតា ខោ មំ សម្ម ឯវមាហ

---

១ ឆ·ម·ជោតុកេសុ ឯវមេវ ន ទិស្សតិ ។

គ្រានោះឯង ព្រះមាតារបស់អនុរុទ្ធសក្កៈទ្រង់ព្រះចិន្តាថា ព្រះកុដិយសក្យ-រាជនេះទ្រង់សោយរាជ្យជាស្តេចរបស់ពួកសក្យៈ ស្តេចនោះជាសំឡាញ់នឹងអនុរុទ្ធសក្កៈ គង់មិនអាចចេញចាកអគារដ្ឋាន ទៅបួសក្នុងសាសនាទេ (លុះទ្រង់ព្រះចិន្តាដូច្នេះហើយ) ទើបមានព្រះសារាសីយទៅនឹងអនុរុទ្ធសក្កៈទៀតថា ម្នាលអនុរុទ្ធ កូន ប្រសិនបើ កុដិយសក្យរាជ ចេញចាកផ្ទះទៅបួសក្នុងសាសនា កាលបើដូច្នេះ សឹមកូនឯងទៅបួសចុះ ។ លំ-ដាប់នោះ អនុរុទ្ធសក្កៈចូលទៅរកព្រះកុដិយសក្យរាជ លុះចូលទៅដល់ហើយទើបថ្វាយសេចក្តីនុ៎ះទៅនឹងកុដិយសក្យរាជថា ម្នាលសំឡាញ់ ការបួសរបស់ខ្ញុំជាប់ទាក់ទងនឹងអ្នក ។ កុដិយសក្យរាជ កំឡើយតបថា ម្នាលសំឡាញ់ បើបព្វជ្ជារបស់អ្នក ជាប់ទាក់ទងនឹងខ្ញុំក្តី មិនជាប់ក្តីបព្វជ្ជានោះចូលលើកទុកចុះ យើងគង់តែនឹងបួសជាមួយអ្នកតាមសប្បាយដែរ ។ អនុរុទ្ធសក្កៈបបួលទៀតថា ម្នាលសំឡាញ់ អ្នកចូរមក យើងទាំងពីរនាក់នឹងចេញចាកផ្ទះទៅបួសក្នុងសាសនា ។ ព្រះកុដិយសក្យរាជតបថា ម្នាលសំឡាញ់ ខ្ញុំមិនអាចចេញចាកផ្ទះទៅបួសក្នុងសាសនាបានទេ កិច្ចឯទៀតដែលខ្ញុំលួងលៃធ្វើជំនួសអ្នកបាន ខ្ញុំនឹងធ្វើជំនួសអ្នក អ្នកចូរបួសចុះ ។ អនុរុទ្ធសក្កៈនិយាយថា ម្នាលសំឡាញ់ ព្រះមាតានិយាយនឹងខ្ញុំយ៉ាងនេះថា

សចេ តាត អនុរុទ្ធ កិន្តិយោ សក្យរាជា អគារស្មា អនគារិយំ បព្វជិតំ វា តុម្ហំ បព្វជាហីតំ ។ ភាសិតា ខោ បន តេ សម្ម វិសា វាចា សចេ តេ សម្ម បព្វជ្ជា មម បដិពន្ធា វា អប្បដិពន្ធា វា សា ហោតុ អហំ តយោ យថាសុខំ បព្វជាមីតំ ។ វិហិ សម្ម ឧភោ អគារស្មា អនគារិយំ បព្វជិស្សាមាតំ ។ តេន ខោ បន សមយេន មនុស្សា សច្ចវាទិនោ ហោន្តិ សច្ចប្បដិញ្ញា-តា[1] ។ អថខោ កិន្តិយោ សក្យរាជា អនុរុទ្ធំ សក្កំ វិតនុភេច អាគមេហិ សម្ម សត្ត វស្សានិ សត្តន្នំ វស្សានំ អច្ចយេន ឧភោបិ អគារស្មា អនគារិយំ បព្វជិស្សាមាតំ ។ អតិចិរំ សម្ម សត្ត វស្សានិ ឆាហំ សក្កោមិ សត្ត វស្សានិ អាគមេតុន្តិ ។ អាគមេហិ សម្ម ឆ វស្សានិ ។ បេ ។ បញ្ច វស្សានិ ចត្តារិ វស្សានិ តីណិ វស្សានិ ទ្វេ វស្សានិ វិតំ វស្សំ វិភាតេ វស្សេ អច្ចយេន ឧភោបិ អគារស្មា អនគារិយំ បព្វជិស្សាមាតំ ។ អតិចិរំ សម្ម វិតំ វស្សំ ឆាហំ សក្កោមិ

---

๑ ខ. ម. សច្ចប្បដិញ្ញា ។

ម្នាលអនុរុទ្ធ បើភទ្ទិយសក្យរាជចេញចាកផ្ទះទៅបួស ក្នុងសាសនា កាល
បើដូច្នោះ អ្នកឯង ចូរបួសចុះ ។ ភទ្ទិយសក្យរាជ ឆ្លើយថា ម្នាល
សំឡាញ់ ខ្ញុំបាននិយាយរាថាន៎ុះចំពោះអ្នកមែនថា ម្នាលសំឡាញ់ បើ
បព្វជ្ជារបស់អ្នកជាប់ពាក់ព័ន្ធនឹងខ្ញុំក្តី មិនជាប់ក្តី បព្វជ្ជានោះលើកទុកទៅ
ចុះ ខ្ញុំគង់តែនឹងបួសជាមួយនឹងអ្នកតាមសប្បាយដែរ ។ អនុរុទ្ធបបួលថា
ម្នាលសំឡាញ់ អ្នកចូរមក យើងទាំងពីរនាក់នឹងចេញចាកផ្ទះទៅបួសក្នុង
សាសនា ។ ក្នុងសម័យនោះ ពួកមនុស្ស ច្រើននិយាយពាក្យសច្ចៈ ប្តេជ្ញា
គ្នាដោយពាក្យសច្ចៈ ។ លំដាប់នោះ ព្រះភទ្ទិយសក្យរាជតបនឹងអនុរុទ្ធសក្កៈ
យ៉ាងនេះថា ម្នាលសំឡាញ់ អ្នកចូរបង្គង់ ៧ ឆ្នាំសិន លុះអាណាំះ ៧ ឆ្នាំទៅ
យើងទាំងពីរនាក់នឹងចេញចាកផ្ទះ ទៅបួសក្នុងសាសនា ។ អនុរុទ្ធសក្កៈ
ឆ្លើយតបថា ម្នាលសំឡាញ់ ៧ ឆ្នាំនោះយូរណាស់ ខ្ញុំមិនអាចនឹងបង្គង់
ចាំដល់ ៧ ឆ្នាំទេ ។ ព្រះភទ្ទិយសក្យរាជ ឆ្លើយថា ម្នាលសំឡាញ់ អ្នក
ចូរធ្វើចាំ ៦ ឆ្នាំចុះ ។បេ។ ៥ ឆ្នាំ ៤ ឆ្នាំ ៣ ឆ្នាំ ២ ឆ្នាំ ១ឆ្នាំចុះ លុះអាណាំះ
១ ឆ្នាំទៅ យើងទាំងពីរនាក់នឹងចេញចាកផ្ទះទៅបួសក្នុងសាសនា។ អនុរុទ្ធ
សក្កៈបបួលទៀតថា ម្នាលសំឡាញ់ ១ ឆ្នាំនោះយូរពេកណាស់ ខ្ញុំមិនអាច

ឯកំ វស្ស អាគមេតុន្តិ ។ អាគមេមិ សម្ម សត្ត មាសេ សត្តន្នំ មាសានំ អច្ចយេន ឧភោបិ អគារស្មា អនគារិយំ បព្ភជិស្សាមាតិ ។ អតិថិរំ សម្ម សត្ត មាសា ខោ សក្កោមិ សត្ត មាសេ អាគមេតុន្តិ ។ អាគមេមិ សម្ម ឆ មាសេ ។ បេ ។ បញ្ច មាសេ ចត្តារោ មាសេ តយោ មាសេ ទ្វេ មាសេ ឯកំ មាសំ អឌ្ឍមាសំ អឌ្ឍមាសស្ស អច្ចយេន ឧភោបិ អគារស្មា អនគារិយំ បព្ភជិស្សាមាតិ ។ អតិថិរំ សម្ម អឌ្ឍមាសោ ខោ សក្កោមិ អឌ្ឍមាសំ អាគមេតុន្តិ ។ អាគមេមិ សម្ម សត្តាហំ យាវាហំ បុត្តេ ច ភាគិនេ ច រជ្ជេ និយ្យាទេស្សាមីតិ[1] ។ ន ចិរំ សម្ម សត្តាហោ អាគមេស្សាមីតិ ។

(៥) អថខោ ភគ្គិយោ ច សក្យរាជា អន្ធុន្ទោ ច អានន្ទោ ច ភគ្គុ ច កិមិលោ ច[2] នេរញ្ជរាយ ច ឧបាលិកប្បកេន សត្តមា យថា បុរេ ច ចតុរង្គិនិយោ សេនាយ ឧយ្យានភូមិ និយ្យន្តិ ឯវមេវ ចតុរង្គិនិយោ

---

๑ ម. ម និយ្យាទេមីតិ ។ ๒ ម. ភគុ ច កិម្ពិលោ ច ។

នឹងរង់ចាំទៅដល់ ១ ឆ្នាំបានទេ ។ ព្រះកុទ្ទិយសក្យរាជអង្គវរទៀតថា ម្នាលសំឡាញ់ អ្នកចូរបង្អង់ ៧ ខែចុះ លុះអំណើះ ៧ ខែទៅ យើងចាំងពីរនាក់នឹងចេញចាកផ្ទះទៅបួសក្នុងសាសនា ។ អនុរុទ្ធសក្កៈតបថា ម្នាលសំឡាញ់ ៧ ខែនោះយូរណាស់ ខ្ញុំមិនអាចនឹងរង់ចាំដល់ទៅ ៧ ខែបានទេ ។ ព្រះកុទ្ទិយសក្យរាជអង្គវរថា ម្នាលសំឡាញ់ អ្នកចូរបង្អង់ដល់ ៦ ខែ រហូត ៥ ខែ ៤ ខែ ៣ ខែ ២ ខែ ១ ខែ កន្លះខែចុះ លុះអំណើះកន្លះខែទៅ សឹមយើងចាំងពីរនាក់ ចេញចាកផ្ទះទៅបួសក្នុងសាសនា ។ អនុរុទ្ធសក្កៈតបទៀតថា ម្នាលសំឡាញ់ កន្លះខែយូរពេកណាស់ ខ្ញុំមិនអាចនឹងរង់ចាំដល់កន្លះខែបានទេ ។ ព្រះកុទ្ទិយសក្យរាជអង្គវរបុះមកទៀតថា ម្នាលសំឡាញ់ អ្នកចូរបង្អង់ ៧ ថ្ងៃសិន ទម្រាំតែខ្ញុំនឹងប្រគល់រាជ្យសម្បត្តិឲ្យកូនប្អូនបង្អួន ។ អនុរុទ្ធសក្កៈទទួលព្រមថា ម្នាលសំឡាញ់ ៧ ថ្ងៃនោះមិនជាយូរប៉ុន្មានទេ ខ្ញុំនឹងរង់ចាំបាន ។

(៩) គ្រានោះឯង (ពួកសក្យៈទាំង ៦ អង្គ) គឺកុទ្ទិយសក្យរាជ ១ អនុរុទ្ធ ១ អានន្ទ ១ ភគ្គុ ១ កិមិល ១ ទេវទត្ត ១ ជាគំរប់ ៧ នាក់នឹងខ្នាន់ព្រះភេសឈ្មោះឧបាលិ ចេញទៅតាន់ទន្សាន មួយអាទ្រីដោយសេនាមានអង្គ ៤ ក្នុងកាលពីដើមយ៉ាងណា សក្យរាជទាំងនោះ យាងចេញទៅ

เสนาย ฉินฺนปิโลติกา ๆ เตน โข ปน สมเยน เสนงฺ นิวตฺถาเปตฺวา ปารุปิตฺวา อากาสณฺ ปุญฺเชตฺวา ทฺวตฺตกฺขตฺตุง ปริวาเรตฺวา กณฺฑิกงฺ ทนฺเตหิ ขาทาปิ กปฺปกงฺ ปตฺตเวฏงฺ ปาทเกหิ อกฺกมาเปตฺวา ทฺวิกฺขตฺตุง ปาทเกหิ อกฺกมาเปตฺวา ปาทเกหิ อกฺกมาเปตฺวา ปาทเกหิ อกฺกมาเปตฺวา

(ដើម្បីបពូជ្ឈមួយអន្លើ) ដោយសេនាមានអង្គ ៤ ក៏យ៉ាងនោះដែរ ។ សក្យៈ
ទាំងនោះ លុះយាងទៅដល់ទីឆ្ងាយ ទើបឲ្យសេនាវិលមកវិញ លុះបួល
ទៅដល់ដែនដទៃហើយ ទើបដោះគ្រឿងប្រដាប់រៃបដាបង្ខែចដោយព្រះ
ពស្ត្រសម្រាប់ពាន រួចហើយទើបមានព្រះបន្ទូលទៅនឹងនាងទាន់ព្រះតេស
ឈ្មោះទុតលិថា នែនាងទុតលិ ណ្ហើយនាងទុតលិ ចូរអ្នកឯងវិលទៅ
វិញចុះ ទ្រព្យប៉ុណ្ណោះគ្រប់មនឹងចិញ្ចឹមជីវិតរបស់អ្នកបានហើយ ។

(៦) គ្រានោះឯង តាលទុតលិតបស្សកៈកំពុងតែដើរវិលមកវិញក៏មាន
សេចក្តីត្រិះរិះយ៉ាងនេះថា ពួកសក្យៈសុទ្ធតែជាអ្នកតាច ។ នឹងសម្លាប់អញ
ក៏បាន ព្រោះគិតថា ទុតលិតបស្សកៈនេះហើយ សម្លាប់ព្រះពាជកុមារ
អម្ប្រាលសក្យកុមារទាំងឡាយ ម្តេចគង់ចេញចាកអគារដ្ឋាន ទៅបួសក្នុង
សាសនាបាន ចំណង់បើអញនឹងបាច់និយាយទៅថ្វី ។ ទុតលិតបស្សកៈនោះ
ក៏ស្រាយបង្ខែចចេញ ហើយតម្បែរបស់នោះលើដើមឈើ ទើបនិយាយថា
បើអ្នកណាឃើញ ចូរលើសយករបស់ដែលអញឲ្យហើយចុះ ហើយដើរបួល
ទៅរកពួកសក្យកុមារវិញ ។ ពួកសក្យកុមារទាំងនោះបានឃើញទុតលិ-
តបស្សកៈកំពុងដើរមកអំពីចម្ងាយហើយ ទើបនិយាយទៅនឹងទុតលិតបស្សកៈ
យ៉ាងនេះថា នែនាងទុតលិ ហេតុដូចម្តេចបានជាអ្នកវិលមកវិញ ។
ទុតលិតបស្សកៈក៏ក្រាបទូលថា បពិត្រព្រះអយ្យបុត្ត តាលដែលខ្ញុំព្រះអង្គ

ฯ ตโต โข สากิยา เจว สากิยานิโย จ สพฺเพ กุมารา จ กุมาริโย จ เยน ภควา เตนุปสงฺกมึสุ ฯ อุปสงฺกมิตฺวา ภควนฺตํ อภิวาเทตฺวา ปริวารยึสุ ฯ ปริวาริตฺวา ภควนฺตํ ปุรตฺถิมายปิ ทิสาย ปจฺฉิมายปิ ทิสาย ฯ ปจฺฉิมายปิ ทิสาย ปุรตฺถิมายปิ ฯ ปุรตฺถิมายปิ ทิสาย อุตฺตรายปิ ทิสาย ฯ อุตฺตรายปิ ทิสาย ปุรตฺถิมายปิ ฯ ปุรตฺถิมายปิ ทิสาย ทกฺขิณายปิ ทิสาย ฯ ทกฺขิณายปิ ทิสาย ปุรตฺถิมายปิ ฯ ปุรตฺถิมายปิ ทิสาย อุปริมายปิ ทิสาย ฯ อุปริมายปิ ทิสาย ปุรตฺถิมายปิ ฯ ปุรตฺถิมายปิ ทิสาย เหฏฺฐิมายปิ ทิสาย ฯ เหฏฺฐิมายปิ ทิสาย ปุรตฺถิมายปิ ฯ

រឿងអំពីទីនេះទៅ កិក្ខុកមានសេចក្តីត្រិះរិះដូច្នេះថា ពួកសក្យរាជសុទ្ធតែ
កាប ។ ន៏ឆ៏សម្ងាប់ខ្ញុំព្រះអង្គចោលក៏បាន ព្រោះគិតថា ខ្ញុំព្រះអង្គនេះ
ហើយដែលសម្ងាប់ព្រះរាជកុមារ អម្បាលពួកសក្យកុមារនេះ(ម្តេចក៏)ចេញ
ចាកអគារដ្ឋាន ទៅបួសក្នុងសាសនា ចុះនឹងចាំស្តាប់ទៅថ្វីដល់ខ្លួនខ្ញុំព្រះអង្គ
បពិត្រព្រះអយ្យបុត្ត ខ្ញុំព្រះអង្គស្រាយបង្វែបចេញហើយ ព្យុរបស់នោះ
លើដើមឈើហើយនិយាយថា បើអ្នកណាឃើញ ចូរប្រើសេយតរបស់
ដែលអញឲ្យហើយចុះ ខ្ញុំព្រះអង្គក៏រំលឹកអំពីទីនោះមកវិញ ។ ពួកសក្យ-
កុមារនិយាយថា នែនាយទុបាលិ ដែលអ្នកត្រឡប់មកវិញនោះឈ្មោះថា
បានធ្វើប្រពៃហើយ ដ្បិតពួកសក្យ:កាប ។ ណាស់ ន៏ឆ៏សម្ងាប់អ្នកចោលក៏
បាន ព្រោះគិតថា អ្នកនេះហើយជាអ្នកសម្ងាប់ព្រះរាជកុមារទាំងឡាយ ។

[៧] គ្រានោះ ពួកសក្យកុមារទាំងនោះនាំទុបាលិកប្បក:ចូលទៅ
គាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំចំពោះ
ព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ ពួកសក្យកុមារទាំងនោះ
លុះអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះ
មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំជាសក្យរាជ តែងមាន
មានះ បពិត្រព្រះអង្គដ៏ចំរើន ទុបាលិកប្បក:នេះជាអ្នកគ្រាប់បម្រើយើងខ្ញុំ
អស់កាលជាអង្វែងមកហើយ សូមព្រះមានព្រះភាគបំបួសទុបាលិកប្បក:

បឋមំ បញ្ហាវេតុ ឥមស្ស មយំ អភិញ្ញេយ្យំ បច្ចុដ្ឋាំ អញ្ញលិតម្បិ សាមីចិកម្បិ តវ សន្តិកេ ឱវទេយ្យ វា អនុសាសេយ្យ វា កុសលេ ច ធម្មេ សមាទបេយ្យ វា សមុត្តេជេយ្យ វា សម្បហំសេយ្យ វាតិ (១) ។ អថ ខោ ភគវា ទុតិយម្បិ តតិយម្បិ បឋមំ បញ្ហាវេសិ បច្ឆា តេ សក្យកុមារេ ។

[៨] អថ ខោ អាយស្មា ភទ្ទិយោ តេនេវ អន្តរវាសេន តិរេស្សំ វិជ្ជា សង្ឃាដិំ ។ អាយស្មា អនុរុទ្ធោ ទិព្ពចក្ខុំ ទុប្បដិវិជ្ឈិ ។ អាយស្មា អានន្ទោ សោតាបត្តិផលំ សច្ឆាកាសិ ។ នេវ ខ្វត្ថ តោ ជុដ្ឋដិកំ ឥត្ថី អភិញ្ញាតេតិ (២) ។

[៩] តេន ខោ បន សមយេន អាយស្មា ភទ្ទិយោ អរញ្ញគតោបិ រុក្ខមូលគតោបិ សុញ្ញាគារគតោបិ អភិក្ខណំ ឧទានំ ឧទានេតិ អហោ សុខំ អហោ សុខន្តិ ។ អថ ខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមិំសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិំសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ

---

១ ម. ប. វិម្ហាបយិស្សតីតិ ។ ម. ប. អភិនិព្ពាទេសិ ។

នេះមុន យើងខ្ញុំនឹងធ្វើនូវអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលីកម្ម នឹងសាមីចិកម្ម ចំពោះទុតលិកប្បកៈនេះ តាលបើយើងខ្ញុំបានធ្វើយ៉ាងនេះហើយ សេចក្តីប្រកាន់ថា ខ្លួនយើងខ្ញុំជាសត្យៈនោះនឹងថយចុះ។ ។ លំដាប់នោះឯង ព្រះមានព្រះភាគបានបំបួសទុតលិកប្បកៈមុន ហើយទើបបំបួសពួកសក្យកុមារទាំងនោះក្រោយ ។

(៨) គ្រានោះ ព្រះកកុឌ្ឋៈដ៏មានអាយុ បានសម្រេចនូវវិជ្ជាបីយ៉ាងខាងក្នុងនៃវស្សានោះឯង ។ ព្រះអនុរុទ្ធដ៏មានអាយុបានសម្រេចទិព្វចក្ខុ។ ព្រះអានន្ទដ៏មានអាយុ បានសម្រេចសោតាបត្តិផល ។ ឯទេវទត្ត បានសម្រេចនូវឫទ្ធិដារបស់បុថុជ្ជន ។

(៩) សម័យនោះឯង ព្រះកកុឌ្ឋៈដ៏មានអាយុទៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី បន្ទូនូវទេវានជារឿយ។ ថា ឱសុខអ្ហីម្ល៉ះ ឱសុខអ្ហីម្ល៉ះ ។ លំដាប់នោះ ពួកភិក្ខុច្រើនរូបចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ ពួកភិក្ខុទាំងនោះ លុះអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគថា

อายสฺมา ภนฺเต ภคฺคโว อาฬวกเตปิ วุตฺตปฺปมาณเตปิ สุญฺญาคารเตปิ อภิกฺขณํ ปิณฺฑาย จรเตปิ อาโรจยามิ ปุพฺพณฺหสมยนฺติ อายสฺมา ภคฺคโว อาฬวกานิ วา ทฺวาทสนิปาตานิ จตฺตาริ จ ปาราชิกาน

បពិត្រព្រះអង្គដ៏ចំរើន ព្រះកុទ្ទិយៈដ៏មានអាយុ ទៅក្នុងព្រៃក្តី នៅគ្រោមម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្ទូនូវទានជារឿយៗថា ឱសុខអ្វីម្ល៉ះ ឱសុខអ្វីម្ល៉ះ បពិត្រព្រះអង្គដ៏ចំរើន ព្រះកុទ្ទិយៈដ៏មានអាយុ ច្រាកដជាអផ្សុកនឹងប្រព្រឹត្តព្រហ្មចរិយធម៌ដោយពិត ពុំនោះសោត លោកលើកនូវសេចក្តីសុខក្នុងការដល់សម្បត្តិពីមុននោះឯង ឋានជាទៅក្នុងព្រៃក្តី នៅគ្រោមម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្ទូនូវទានជារឿយៗថា ឱសុខអ្វីម្ល៉ះ ឱសុខអ្វីម្ល៉ះ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុ ១ រូបមក ហើយបង្គាប់ថា ម្នាលភិក្ខុ អ្នកចូរមក ចូរអ្នកទៅហៅកុទ្ទិយភិក្ខុតាមពាក្យតថាគតថា ម្នាលអាវុសោកុទ្ទិយៈ ព្រះសាស្តាទ្រង់ឲ្យហៅអ្នក ។ ភិក្ខុនោះទទួលស្តាប់ព្រះពុទ្ធដីការនៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន យ៉ាងនេះហើយ ក៏ចូលទៅរកកុទ្ទិយភិក្ខុដ៏មានអាយុ លុះចូលទៅដល់ហើយ ទើបនិយាយពាក្យនេះនឹងកុទ្ទិយភិក្ខុដ៏មានអាយុថា ម្នាលអាវុសោកុទ្ទិយៈ ព្រះសាស្តាត្រាស់ហៅអ្នក ។

(๑๐) ព្រះកុទ្ទិយៈដ៏មានអាយុ ទទួលស្តាប់ពាក្យរបស់ភិក្ខុនោះថា ម្នាលអាវុសោ ដូច្នេះហើយ ក៏ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។

ฝกมฺมฺ ฉสิฺฐฺ เอ ภาย สฺฐฺ ภฺฐิยฺ ภกภา ฝสฺส-
ภเว สพฺพ ภาว ตฺวิ ภฺฐิย ภาย ฉญฺญกเตเน ปุคฺคลิก-
เตเน สฺุญาตาภกเตเน ภกิกฺขณี ๆ ฐาตพฺพ ๆ ฐาเนสิ
ภเย สุขี ภเย สุขิตฺถิ ๆ ฝภฺภนฺเตติ ๆ ภกิ ปน
ตฺวิ ภฺฐิย ภตฺถาสี สมฺปฺปชานา ภาย ฉญฺญกเตเน ปุคฺค-
ลิกเตเน สฺุญาตาภกเตเน ภกิกฺขณี ๆ ฐาตพฺพ ๆ ฐา-
เนสิ ภเย สุขี ภเย สุขิตฺถิ ๆ ปุเพฺพ เม ภนฺเต
ภญฺญา สเตเน[๑] ภนฺเตเน ภนฺเตปุเร ภกฺขา สุสีลา
เหาติ ตเทเน ภนฺเตปุเร ภกฺขา สุสีลา เหาติ
ภนฺเตเน ฉภเร ภกฺขา สุสีลา เหาติ ตเทเน
ฉภเร ภกฺขา สุสีลา เหาติ ภนฺเตเน ฉนปเท
ภกฺขา สุสีลา เหาติ ตเทเน ฉนปเท ภกฺขา
สุสีลา เหาติ เสา เอ ภยิ ภนฺเต ฝภ
ภกฺขิเตเน เตเนเตเน สงฺโฆ ภีเต ฐิโตฺถ ฐสฺสติ
ฐตฺรสฺเถ วิหาเรเน ฝตรเน เอ ปฺปาปิตา[๒]
ภนฺเต ภาย ฉญฺญกเตเน ปุคฺคลิกเตเน สฺุญาตาภกเตเน

๑ ฉ. ม. ภญฺญา สเตเน ฯ ๒ ฉ. ม. เอตฺถเนฺตสุ ภยิ สเตฺถ ฐตฺวิ ฯ

ព្រះមានព្រះភាគ ឃាន់ត្រាស់ព្រះតម្រាស់នេះនឹងព្រះកុំយៈដ៏មានអាយុ ដែលអង្គុយក្នុងទីដ៏សមគួរថា ម្នាលកុំយៈ ឃាន់ឮថា អ្នកទៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្ទឹមទានជារឿយ ៗ ថា នុសុខអ្វីម៉្លេះ នុសុខអ្វីម៉្លេះ ពិតមែនឬ ។ កុំយៈក៏ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ពិតមែន ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលកុំយៈ ចុះអ្នកពិចារណាឃើញអំណាចប្រយោជន៍យ៉ាងណា ឃានជាអ្នកទៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្ទឹមទានជារឿយ ៗ ថា នុសុខអ្វីម៉្លេះ នុសុខអ្វីម៉្លេះ ដូច្នេះ ។ កុំយៈក៏ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន កាលពីដើមខ្ញុំព្រះអង្គនៅជាស្តេច ការពារក្នុងព្រះរាជវាំង គេឃានចាត់ចែងល្អ ការពារក្រៅព្រះរាជវាំង គេឃានចាត់ចែងល្អ ការពារក្នុងនគរ គេឃានចាត់ចែងល្អ ការពារក្រៅនគរ គេឃានចាត់ចែងល្អ ការពារក្នុងជនបទ គេឃានចាត់ចែងល្អ ការពារក្រៅជនបទ គេក៏ឃានចាត់ចែងល្អ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនោះឯង ជាមនុស្សដែលគេការពារមកយ៉ាងនេះផង គ្រប់គ្រងយ៉ាងនេះផង គង់នៅមានខ្លាច ញាប់ញ័រ រន្ធត់ តក់ស្លុត បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ខ្ញុំព្រះអង្គតែម្នាក់ឯង ក៏ទៅក្នុងព្រៃក្តី ទៅក្រោមម្លប់ឈើក្តី ទៅក្នុងផ្ទះស្ងាត់ក្តី

อภีตเร อนุฆฺเฏฏา อนุสฺสุกฺกี อนุทฺธตเสฺต อเปฺปสกฺขา (๑)
ปฏฺฐเลาเหา ปรเชตวฺวาฏา มิคกฺขเตน เชตสา วิหารมีตี
สมิ เหา อหาสิ ภณฺเฑ อตฺถาสิ สงฺฆสฺสเปโหเน อรญฺญเก-
เต ฯ เป ฯ อภิกฺกมณาสิ ทุฆาสิ ทุฆาเนมิ อเปหา สุขี
อเปหา สุขฏฺฐี ฯ อถเหา ภควา เอตมตฺถี วิทิตฺวา ตายี
เวลายี สมิ ทุฆาสิ ทุฆาเนสิ

(๑๑) ยสนฺตเร น สนฺถิ เหาจา

สหิภาภาเรตฺวา วีติวาเฏา
สิ วิเตตภายี สุขี อเสาเกา
เนวา ชานุภวฺฐิ ธเสฺสเยโต ฯ

(๑๒) อถเหา ภควา อนุปิเยายี ยเชาภิรฺฐี วิหา-
รตฺถา เยน เหาสมฺพี เตน จาริกี ปกฺกามิ อนุปุพฺเพน
จาริกี จรมาเหา เยน เหาสมฺพี ตทวสริ ฯ ตตฺร สุที
ภควา เหาสมฺพิยี วิหารติ เยาสิตาภเย ฯ

---

๑ ฉ. ม. เชตวเนสุ ตถิสเทฺว นตฺถิ ฯ

កំឥតភ្ងាប ឥតញាប់ញ័រ ឥតរន្ធត់ តក់ស្លុតឡើយ ជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច ជាបន្ទុស្សសម្បបវេប ចំពើមដីតែដោយចតុប្បច្ច័យដែលបុគ្គលដាំឲ្យ មានចិត្តដូចជាពួកសត្វម្រឹគ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គពិចារណាឃើញនូវអំណាចប្រយោជន៍យ៉ាងនេះហើយ ទើបបានទៅក្នុងព្រៃក្តី ។បេ។ តែងបន្ទូទានដាវឿយ ។ ថា ឧសុខអ្ហ៊ីម្ល៉ះ ឧសុខអ្ហ៊ីម្ល៉ះ ដូច្នេះ ។ លំដាប់នោះ ព្រះមានព្រះភាគជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទ្រង់បន្ទូនូវទានេះ ក្នុងវេលានោះថា

(๑๑) សេចក្តីក្រោធមិនមានក្នុងចិត្តរបស់អ្នកណា អ្នកនោះឈ្មោះថា កន្ទួងដុតនូវសេចក្តីចំរើនធំ សេចក្តីវិនាស ប្រើនប្រការ ទេវតាទាំងពួង តំកម្រើនធំបានឃើញនូវអ្នកដែលមានភ័យកន្ទួងដុតហើយ បានប្រកបដោយសេចក្តីសុខ ឥតមានសេចក្តីសោកនោះឡើយ ។

(๑๒) គ្រានោះឯង ព្រះមានព្រះភាគ ព្រះអង្គគង់នៅក្នុងព្រៃអនុបិយា គួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់យាងសំដៅទៅកាន់ចារិកនគរកោសម្ពី ត្រាច់ទៅកាន់ចារិកតាមលំដាប់ ឆ្ពោះទៅនគរកោសម្ពី ។ បានត្រាស់ថា ព្រះមានព្រះភាគទ្រង់សម្រេចព្រះឥរិយាបថ ក្នុងយោសិតារាមខៀបនគរកោសម្ពីនោះ ។

[๑๓] อถโข เถรสฺส ปโยคสมฺปนฺนสฺส ปฏิสลฺลี-นสฺส เอวเมตสฺส ปริวิตกฺโก อุทปาทิ กถํ นุ โข อหเมว ปสาเธยฺยํ ยสฺมึ เม ปสนฺเน พหู ลาภสกฺกาเร อุปฺปชฺเชยฺยุนฺติ ฯ อถโข เถรสฺส เอตทโหสิ อยเมว โข อชาตสตฺตุ กุมาโร ตรุโณ เจว อายตึ กลฺยาณาธิปฺปายา ยนฺนูนาหเมว อชาตสตฺตุ กุมารํ ปสาเธยฺยํ ตสฺมึ เม ปสนฺเน พหู ลาภสกฺกาเร อุปฺปชฺเชยฺยุนฺติ ฯ อถโข เถรสฺส เสตจฺฉตฺตสมีเป สมีปาเมตฺวา ปตฺตจีวรมา-ทาย เยน ภาสกฬาวนมิคทายโก เตนุปสงฺกมิ อนุปุพฺเพน เยน ภาสกฬาวนมิคทายโก เตนุปสงฺกมิ ฯ อถโข เถรสฺส สกวาทิโน ปฏิสนฺถารตฺถา กุมารวณฺณา อภิณฺหปฺปวตฺตา อหิเมว[1] ลิงฺคาย อชาตสตฺตุสฺส กุมารสฺส อุจฺจาเรนฺติ ฯ อถโข อชาตสตฺตุ กุมาโร ภีโต อโหสิ อุพฺพิคฺโค อุสฺสงฺกี อุตฺตฺรสฺโต ฯ อถโข เถรสฺส อชาตสตฺตุ กุมารํ ปสาเธสิ ภายสิ มหาราช กุมาร ภายาหิ ฯ อหเมตฺถ ตาเยหิ ตาณาย โสตฺถิยา ฯ อหเมว ตาเยหิ ตาณาติ ฯ

---

๑ ฉ. ม. อุจฺจาเรนฺติ ฯ

[១៣] គ្រានោះ ទេវទត្តទៅក្នុងទីស្ងាត់ សម្ងំទៅក្នុងទីស្ងាត់ កើតសេចក្តីត្រិះរិះក្នុងចិត្តយ៉ាងនេះថា អញនឹងឲ្យអ្នកណាជ្រះថ្លាហ ុ តាលបើអ្នកណាកើតចិត្តជ្រះថ្លាចំពោះអញ លាភសក្ការៈច្រើន មុខជានឹងកើតដល់អញពុំខាន ។ គ្រានោះ ទេវទត្តមានសេចក្តីត្រិះដូច្នេះថា អជាតសត្តុកុមារនេះទៅក្នុងផង មានសេចក្តីចំរើនតទៅទៀតផង បើដូច្នោះគួរអញឲ្យអជាតសត្តុកុមារជ្រះថ្លា តាលបើអជាតសត្តុកុមារនោះ មានចិត្តជ្រះថ្លាចំពោះអញហើយ លាភសក្ការៈច្រើន មុខជានឹងកើតឡើងដល់អញ ។ លំដាប់នោះ ទេវទត្តរៀបចំអាសនៈប្រដាប់ដោយគ្រឿងសំដៅទៅនគរពន្លឺតាមលំដាប់លំដោយ ឆ្ពោះទៅនគរពន្លឺនោះ ។ គ្រានោះ ទេវទត្តដំណើរទេកខ្លួនទំបិតទ្លើជាក្មេងគួបពាក់សង្ឃវាសស្រាប់តែទៅអង្គុយលើភ្លៅអជាតសត្តុកុមារភ្លាម ។ គ្រានោះ អជាតសត្តុកុមារក៏ខ្ចាបញ្ចាប់ញ័រន្លត់តក់ស្លុត ។ លំដាប់នោះ ទេវទត្តបាននិយាយពាក្យនេះនឹងអជាតសត្តុកុមារថា បពិត្រកុមារ ព្រះអង្គខ្ចាបអាត្មាឬ ។ អជាតសត្តុកុមារឆ្លើយថា អើខ្ចាប ចុះអ្នកជាអ្វី ។ ទេវទត្តថា អាត្មានេះជាកិត្តិឈ្មោះទេវទត្ត ។

สเจ ขเว ตุมฺเห ภนฺเต อยฺยา เทวทตฺตสฺส สงฺฆ สเมตาเทว
วณฺณ ภาสิสฺสถ ๆ อถโข เทวทตฺโต กุมารกสฺส ปฏิสมฺปวาเรสิ
สงฺฆ ภนฺเต ปุตฺโต อชาตสตฺตุสฺส กุมารสฺส ปุตฺโต อชาตสตฺตุ กุมาโร
เทวทตฺตสฺส ๆ ตมฺปิ ๆ ทิฏฺปฏิสาโร ยเน อภิปฺปสนฺโน
ปญฺจหิ รถสเตหิ สายณฺหสมยณฺ ภควโต ปฏิสนฺถาร
ปาลิภาคสฺส สาธุ ภทฺทกมิจฺเจว อภิมาโร ๆ อถโข
เทวทตฺตสฺส ลาภสกฺการสิโลกสฺส อภิภูตสฺส ปริ-
โยนทฺธจิตฺตสฺส เอวรูป ปาปก อิจฺฉาคต อโหสิ อหเมว
ปริหาริสฺสามีติ สงฺฆ ภินฺทิตฺวา ๆ เทวทตฺโต ตสฺส
ภิกฺขุโน ปริหาย ๆ

[๑๔] เตน โข ปน สมเยน กกฺกฏโก[1] นาม
โกลฺลิยปุตฺโต อายสฺมโต มหาโมคฺคลฺลานสฺส ปุพ-
ฺพโก กลฺยาณสหาโย โหติ สนฺทิฏฺโ เจว สมฺภตฺโ จ
ยาวเทว พฺรหฺมจริยาย ๆ อถโข กกฺกฏโก นาม โกลฺลิยปุตฺโต
เยน เทวทตฺโต ตเยน อุปสงฺกมิ อุปสงฺกมิตฺวา เทวทตฺต
อภิวาเทตฺวา เอกมนฺต นิสีทิ ๆ เอกมนฺต นิสินฺโน โข
กกฺกฏโก นาม โกลฺลิยปุตฺโต เทวทตฺต เอตทโวจ

๑ ม. ม กกโฏ ๆ

សង្ឃភេទកូនក្មេង រឿងកូនអ្នកស្រុកកោឡិយៈ ឈ្មោះកកុធៈ

អជាតសត្តុកុមារថា បពិត្រលោកម្ចាស់ បើលោកម្ចាស់ឈ្មោះទេវទត្ត
មែន សូមផ្ញើសមកជាកេរបស់ខ្លួនវិញមើល ។ គ្រានោះ ទេវទត្តផ្ញើស
កេរក្មេងគួចចេញហើយ ត្រឡប់មកជាភិក្ខុ ទ្រទ្រង់សង្ឃដិបាត្រនឹងចីវរ
ឈរពីខាងមុខអជាតសត្តុកុមារ ។ លំដាប់នោះ អជាតសត្តុកុមារមានចិត្ត
ជ្រះថ្លាពេក ដោយឥទ្ធិប្បាដិហារ្យនេះរបស់ទេវទត្ត ហើយតែងទៅដោយ
រថច្រាំរយ បម្រើពាំងល្ងាចពាំងព្រឹក ពាំងឲ្យអ្នកនាំសម្រាប់ យកសម្រាប់
ច្រាំរយថាសទៅផង ។ គ្រានោះ ទេវទត្តដែលលាភសក្ការៈនឹងសេចក្តី
សរសើរគ្របសង្កត់ហើយ កំមានចិត្តច្រៃប្រួល គ្មើតមានសេចក្តីច្រាថ្នា
មានសភាពយ៉ាងនេះថា អញនឹងគ្រប់គ្រងនូវភិក្ខុសង្ឃ ដូច្នេះ ទេវទត្តកំ
សាបសូន្យចាកឫទ្ធិនោះ ក្នុងពេលជាមួយនឹងអកុសលចិត្តគ្មើតឡើង ។

(១៤) សម័យនោះឯង មានកូនអ្នកស្រុកកោឡិយៈម្នាក់ឈ្មោះកកុធៈជា
ឧបដ្ឋាករបស់ព្រះមហាមោគ្គល្លានដ៏មានអាយុ ទើបនឹងស្ទាបភ្លាមហើយបាន
ទៅកើតជាទេវតាយដែលសម្រេចដោយចិត្តមួយអង្គ ។ ទេវបុត្តនោះបាន
នូវអត្តភាពមានសភាពយ៉ាងនេះ ដូចជាបានតាមក្តេរបស់អ្នកស្រុកមគធៈ
ពីរឬបី ។ លោកមិនដែលបៀតបៀនខ្លួនឯងនឹងអ្នកដទៃ ដោយអាងបាន

อตฺตานํ น ปริหรามาเตติ ฯ อถโข กกฺกโฏ เถร-
ปุตฺโต เยนายสฺมา มหาโมคฺคลฺลาโน เตนุปสงฺกมิ
อุปสงฺกมิตฺวา อายสฺมโต มหาโมคฺคลฺลานสฺส อภิวาเทตฺวา
เอกมนฺตํ อฏฺฐาสิ ฯ เอกมนฺตํ ฐิโตฺ โข กกฺกโฏ
เถรปุตฺโต อายสฺมโต มหาโมคฺคลฺลานสฺส เอตทโวจ เถร-
ทสฺสนกาเมฺห โข มยา กสกฺการสิโลเกน อภิภูตสฺส ปริ-
ยาทินฺนจิตฺตสฺส เอวรูปา ๙ปฺปาทตา อุปฺปชฺชิ อหา ภิกฺขุสงฺฆ
ปริหารสฺสาหมีติ สหา จิตฺตุปฺปาทา วา ภนฺเต เถรทสฺ-
ตสฺสา ๙นฺตรา ปริหีโนติ ฯ ๙ถมโวจ กกฺกโฏ
เถรปุตฺโต ๙ตฺถ วา อายสฺมโต มหาโมคฺคลฺลานสฺส
อภิวาเทตฺวา ปนตฺถิกา ภควา ตตฺเถว อนฺวายนฺติ ฯ

(๑๙) อถโข อายสฺมา มหาโมคฺคลฺลาโน เยน
ภควา เตนุปสงฺกมิ อุปสงฺกมิตฺวา ภควนฺตํ อภิวาเทตฺวา
เอกมนฺตํ นิสีทิ ฯ เอกมนฺตํ นิสินฺโน โข อายสฺมา
มหาโมคฺคลฺลาโน ภควนฺตเมตทโวจ กกฺกโฏ ภนฺเต
ภนฺเต ภาคฺยปุตฺโต มม อุปชฺฌาโย อหุ ภนฺเต ภาคฺย-
ภาโค อญฺญตรํ มหาชนยญฺญ ภาคยญฺ อุปปนฺโน ตสฺส

អត្តភាពនោះទេ ។ គ្រានោះ តក្កធទេវបុត្ត ចូលទៅរកព្រះមហាមោគ្គល្លាន ដ៏មានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមហាមោគ្គល្លានដ៏មានអាយុ ហើយទើបឈរក្នុងទីសមគួរ ។ លុះតក្កធទេវបុត្តឈរក្នុងទីសមគួរហើយ បានថ្លែងពាក្យនេះនឹងព្រះមហាមោគ្គល្លានដ៏មានអាយុថា បពិត្រលោកម្ចាស់(ឥឡូវ) ទេវទត្តត្រូវលោកសក្ការៈនឹងសេចក្តីសរសើរគ្រប់សង្កត់ហើយ មានចិត្តប្រែប្រួល កើតមានសេចក្តីច្រឡាំងថ្នាំងមានសភាពយ៉ាងនេះថា អញនឹងរក្សាទុកនូវកិក្ខុសង្ឃ បពិត្រលោកម្ចាស់ ទេវទត្តសាបសូន្យចាកឫទ្ធិនោះ ក្នុងវេលាជាមួយនឹងអកុសលចិត្តកើតឡើង ។ តក្កធទេវបុត្តបានថ្លែងពាក្យនេះលុះថ្លែងពាក្យនេះហើយ ក៏ក្រាបថ្វាយបង្គំលាព្រះមហាមោគ្គល្លានដ៏មានអាយុ ធ្វើប្រទក្សិណហើយស្រាប់តែបាត់ពីទីនោះទៅ ។

(១៥) គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះមហាមោគ្គល្លានដ៏មានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កូនអ្នកស្រុកកោឡិយៈម្នាក់ឈ្មោះតក្កធៈជាឧបដ្ឋាករបស់ខ្ញុំព្រះអង្គ ទើបនឹងស្លាប់អំបាញ់មិញ បានទៅកើតជាទេវកាយដែលសម្រេចដោយចិត្តមួយអង្គ ទេវបុត្តនោះ បានអត្តភាពយ៉ាងនេះ

ឃវាតោ អត្តភាវប្បដិលាភោ សេយ្យថាបិ នាម ទ្វេ ភាតិកា ភ មាគធិកានំ កាមភោគ្គានំ សោ តេន អត្ត-
ភាវប្បដិលាភេន ទេវ អត្តានំ ន បរំ ព្យាពាធេតិ អថខោ
កន្តេ កក្កោ ទេវបុត្តោ យេនាហំ តេនុបសង្កមិ
ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ឯកមន្តំ
ឋិតោ ខោ កន្តេ កក្កោ ទេវបុត្តោ មំ ឯតទវោច
ទេវ ធម្មសវ្ហ កន្តេ លាភសក្ការសិលោកេន អភិភូតស្ស
បរិយោនទ្ធចិត្តស្ស ឃវ្ហ ឥទ្ធាគតំ ឧប្បន្នំ អហំ ភិក្ខុសង្ឃំ
បរិហរិស្សាមីតិ សមា ចិត្តុប្បាទា វ កន្តេ ទេវធម្មោ តស្ស
ឥទ្ធិយោ បរិហីនោតិ ឥទមវោច កន្តេ កក្កោ ទេវបុត្តោ
ឥទ វត្វា មំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវ
អន្តរធាយីតិ ។ តតំ បន តេ មោគ្គល្លាន កក្កោ
ទេវបុត្តោ ចេតសា ចេតោ បរិច្ចវិទិនោ យន្តិញ្ចិ កក្កោ
ទេវបុត្តោ ភាសតិ សព្ពន្តំ តថេវ ហោតិ នោ អញ្ញថាតិ ។
ចេតសា ចេតោ បរិច្ចវិទិនោ វ មេ កន្តេ កក្កោ
ទេវបុត្តោ យន្តិញ្ចិ កក្កោ ទេវបុត្តោ ភាសតិ សព្ពន្តំ
តថេវ ហោតិ នោ អញ្ញថាតិ ។ វក្ខស្សតំ មោគ្គល្លាន

ដូចជាបានតាមក្តៅត្តរបស់អ្នកស្រុកមគធ:ពីរឬបី ទេវបុត្តនោះមិនដែលបៀត
បៀនខ្លួនឯងឆន្ទឆ៍អ្នកដទៃ ដោយអាឆ៍បានអត្តភាពនោះទេ បពិត្រព្រះអង្គដ៏
ចំរើន គ្រានោះ កកុធទេវបុត្តចូលមកគាល់ខ្ញុំព្រះអង្គ លុះមកដល់ហើយថ្វាយ
បង្គំចំពោះខ្ញុំព្រះអង្គ រួចស្រែចតំណែងក្នុងទីដ៏សមគួរ លុះណែងក្នុងទីដ៏សមគួរ
ហើយបានថ្លែងពាក្យនេះនឹងខ្ញុំព្រះអង្គថា បពិត្រលោកម្ចាស់ (ឥឡូវនេះ)
ទេវទេត្តត្រូវលោកសក្ការ:ធឆ៍សេចក្តីសរសើរគ្រប់សង្កត់ហើយ មានចិត្តប្រែ
ប្រួល តើតមានសេចក្តីត្រាថ្នាមានសភាពយ៉ាឆ៍នេះថា អញនឹងគ្រប់គ្រង
នូវកិក្ខុសង្ឃ បពិត្រលោកម្ចាស់ ទេវទេត្តសាបសូន្យចាកឫទ្ធិនោះ ក្នុង
វេលាជាមួយនឹងអកុសលចិត្តតើតឡើង បពិត្រព្រះអង្គដ៏ចំរើន កកុធទេវ-
បុត្តបានថ្លែងពាក្យនេះ លុះថ្លែងពាក្យនេះហើយ ទើបក្រាបថ្វាយបង្គំលាខ្ញុំ
ព្រះអង្គ ធ្វើប្រទក្សិណហើយក៏បាត់ពីទីនោះឯង ។ ព្រះអង្គទ្រង់ត្រាស់សួរ
ថា ម្នាលមោគ្គល្លាន កកុធទេវបុត្ត អ្នកបានតំណាត់ដឹងចិត្តដោយចិត្តឬស
ហើយឬ តកុធទេវបុត្តនិយាយពាក្យណាមួយ ពាក្យនោះជាពាក្យពិត
ឬជាពាក្យកំភូតទេ ។ ព្រះមហាមោគ្គល្លានក្រាបបង្គំទូលថា បពិត្រព្រះអង្គ
ដ៏ចំរើន ខ្ញុំព្រះអង្គតំណាត់ដឹងចិត្តដោយចិត្តឬសថា កកុធទេវបុត្តនិយាយ
ពាក្យណាមួយ ពាក្យទាំងនោះជាពាក្យពិតហើយ មិនមែនជាពាក្យកំភូត
ទេ ។ ព្រះ ឆ្ពុទ្ធទ្រង់ត្រាស់ថា ម្នាលមោគ្គល្លាន ចូរអ្នកវក្បាខ្ពុកនូវសំដី ន ឆ្ពុះ

ភិក្ខំ រក្ខសេ្ចតំ មោក្ខល្លាន ភិក្ខំ ឥទានិ សោ មោឃ-
បុរិសោ អត្តានំ វ អត្តានំ ទាតុកាវសេ្ចតិ ។

(๑๖) បញ្ចិមេ មោក្ខល្លាន សត្តាភេ សង្ឃេ សំវិជ្ជ-
មានេ លោកស្មិំ ។ កតមេ បញ្ច ។ ឥធ មោក្ខល្លាន
ឯកច្ចោ សត្តា អបរិសុទ្ធសីលោ សមានោ បរិសុទ្ធសី-
លោម្ហីតិ បដិជានាតិ បរិសុទ្ធំ មេ សីលំ បរិយោទាតំ
អសង្កិលិដ្ឋន្តិ ច[1] ។ តមេនំ សាវកា ឯវំ ជានន្តិ អយំ
ខោ ភវំ សត្តា អបរិសុទ្ធសីលោ សមានោ បរិសុទ្ធសី-
លោម្ហីតិ បដិជានាតិ បរិសុទ្ធំ មេ សីលំ បរិយោទាតំ
អសង្កិលិដ្ឋន្តិ ច[2] មយំ ចេវ ខោ បន តិហីនំ អារោ-
ចេយ្យាម ជានស្សុស្សុ មានាបំ យំ ខោ បនស្ស អមនាបំ
កថន្តិ[3] មយំ តេន សមុទាចរេយ្យាម សម្ផន្តិ ខោ
បន ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជប-
រិក្ខារេន យំ តុមោ[4] ភវិស្សតិ តុមោ[5] វ តេន បញ្ញា-
យិស្សតីតិ ។ ឯវរូបំ ខោ មោក្ខល្លាន សត្តារំ សាវកា
សីលតោ រក្ខន្តិ ។ ឯវរូបោ ច បន សត្តា សាវកេហិ
សីលតោ រក្ខិតំ បច្ចាសីសតិ ។

๑-๒ ឧ. ម. ភោត្តភេសុ ចសទ្ទោ ន បញ្ញាយតិ ។ ๓ ឧ. កថំ នំ ។ ๔-๕ ប. តុម្ហេ

ម្នាលមោគ្គល្លាន ចូរអ្នកកុំក្រេវក្រាំនូវសំដីនេះចុះ ដ្បិតឥឡូវនេះ មោឃបុរស នោះ ធ្លាប់ខ្ជិនឲ្យល្បីដោយខ្ជិនឯង ។

[๑๖] ម្នាលមោគ្គល្លាន គ្រូក្នុងលោកនេះមាន ៥ ពួក ។ គ្រូ ទាំង ៥ ពួកនោះគឺគ្រូណាខ្លះ ។ ម្នាលមោគ្គល្លាន គ្រូពួកមួយ ក្នុងលោក នេះ មានសីលមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានសីលបរិសុទ្ធខ្លះ ថាសីល របស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ។ សាវ័កទាំងឡាយតែង ដឹងគ្រូ នោះយ៉ាងនេះ ថា គ្រូដ៏ចំរើននេះ មានសីលមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានសីលបរិសុទ្ធខ្លះ ថាសីលរបស់អញបរិសុទ្ធផូរផង់ ឥតមានសៅ ហ្មងខ្លះ ដូច្នេះ តែថាបើយើងប្រាប់ (រឿងនោះ) ដល់ពួកគ្រហស្ថ ឬ លោកមិនគាប់ចិត្តទេ ក៏រឿងណាមិនគាប់ចិត្តដល់លោក យើងនឹងសុំ រឿងលោក នោះដូចម្តេចបាន ព្រោះ លោកកំពុងតប់អាន (យើង) ដោយ ចីវរ បិណ្ឌបាត សេនាសន និងគិលានប្បច្ចយភេសជ្ជបរិក្ខារ លោកនឹងធ្វើ តម្មណា លោកគង់នឹងប្រាសចេញដោយតម្មនោះមិនខាន ។ ម្នាលមោគ្គល្លាន សាវ័កទាំងឡាយតែងរក្សាគ្រូបែបនេះដោយសីល ។ ឯគ្រូមានសភាព យ៉ាងនេះ តែងនឹកសង្ឃឹមនូវការរក្សា អំពីពួកសាវ័កដោយសីល ។

[๑๗] ปุน จปรํ โมคฺคลฺลาน สตฺเถกจฺโจ สตฺถา อปริสุทฺธาชีโว สมาโน ปริสุทฺธาชีวมฺหีติ ปฏิชานาติ ปริสุทฺโธ เม อาชีโว ปริโยทาโต อสงฺกิลิฏฺโฐติ จ ฯ ตเมนํ สาวกา ฬหํ ชานนฺติ อยํ โข กิร สตฺถา อปริสุทฺธาชีโว สมาโน ปริสุทฺธาชีวมฺหีติ ปฏิชานาติ ปริสุทฺโธ เม อาชีโว ปริโยทาโต อสงฺกิลิฏฺโฐติ จ มยํ เจว โข ปน ตถาตฺตาย อาเรเจยฺยาม ตาสฺวสฺส มนาปา มยิ โข ปนสฺส อมนาปา กถญฺหิ มยิ สนฺเต สมุทาจเรยฺยาม สทฺธนฺติ โข ปน จีวรปิณฺฑปาตเสนาสนคิลานปจฺจยเภสชฺชปริกฺขารเหตุ ยํ ตุมฺเห กเรยฺยาถ ตุมฺหากเมว ปญฺญายิสฺสตีติ ฯ ฬหฺหปิ โข โมคฺคลฺลาน สตฺถารํ สาวกา อาชีวเหตุ รกฺขนฺติ ฯ ฬหฺหาปิ จ ปน สตฺถา สาวเกหิ อาชีวเหตุ รกฺขิโต ปฏิสีสติ ฯ

[๑๘] ปุน จปรํ โมคฺคลฺลาน สตฺเถกจฺโจ สตฺถา อปริสุทฺธมฺหิโนสมาโน สมาโน ปริสุทฺธมฺหิโนสมาโน-มฺหีติ ปฏิชานาติ ปริสุทฺโธ เม ธมฺหิโนสมา ปริโยทาตา

[១៧] ម្នាលមោគ្គល្លាន ពាក្យដទៃនៅមានទៀត គ្រូពួកមួយក្នុងលោកនេះ មានអាជីវៈមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានអាជីវៈបរិសុទ្ធខ្លះ ថាអាជីវៈរបស់អញបរិសុទ្ធផ្លូវផង់ឥតមានសៅហ្មងខ្លះ ។ ពួកសាវ័កដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើននេះ មានអាជីវៈមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានអាជីវៈបរិសុទ្ធខ្លះ ថាអាជីវៈរបស់អញបរិសុទ្ធផ្លូវផង់ឥតមានសៅហ្មងខ្លះ ដូច្នេះ តែថាបើយើងប្រាប់ (រឿងនោះ) ដល់ពួកគ្រហស្ថ គង់លោកមិនគាប់ចិត្តទេ ក៏រឿងណាមិនគាប់ចិត្តដល់លោក យើងនឹងសើរើរឿងលោកនោះដូចម្តេចបាន ព្រោះលោកកំពុងតែបន្ថែមអាន(យើង) ដោយចីវរ បិណ្ឌបាត សេនាសនៈនឹងគិលានប្បច្ចយភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណាគង់លោកនឹងប្រាកដដោយកម្មនោះមិនខាន ។ ម្នាលមោគ្គល្លាន សាវ័កទាំងឡាយតែងរក្សាគ្រូបែបនោះដោយអាជីវៈ ។ឯគ្រូមានសភាពយ៉ាងនេះ តែងទឹកសង្ឃឹមនូវការរក្សាអំពីពួកសាវ័កដោយអាជីវៈ ។

[១៨] ម្នាលមោគ្គល្លាន ពាក្យដទៃនៅមានទៀត គ្រូពួកមួយក្នុងលោកនេះ មានធម្មទេសនាមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានធម្មទេសនាបរិសុទ្ធខ្លះ ថាធម្មទេសនារបស់អញ បរិសុទ្ធផ្លូវផង់ ឥតមាន

อสงฺกิลิฏฺฐาตา จ ฯ ตเมนํ สาวกา ฯเปฯ ชานนฺติ อยมฺปิ โข ภวํ สตฺถา อปริสุทฺธกายสมาจาโร ปริสุทฺธกายสมาจารสฺสปิ ตาทิสสฺส ปริสุทฺธกายสมาจารตา ปญฺญายติ ปริสุทฺธา เม กายสมาจารตา อสงฺกิลิฏฺฐาตา จ มยมฺปิ เขฬา โนปิ ตาทิสา อาเกเตยฺยาม ทาสฺสฺสฺส มกาโม ยมฺปิ โข ปนสฺส อมกาโม ภวิสฺสติ มยา เนว สมุทาจเรยฺยาม สมฺมุขาปิ โข ปน ตีหิวาปิ ญาตเสนาสนกิลานปฺปฏิยตฺเตหิ นิมนฺเตยฺยาม ตุเมหิ ภวิสฺสติ ตุเมหิ วา เนว ปญฺญายิสฺสตีติ ฯ ฯเปฯ โข มหาปณฺฑิโต สตฺถารา สาวกานํ ธมฺมเนตฺติ ฯ ฯเปฯ โข จ ปน สตฺถา สาวเกหิ ธมฺมเนตฺติ ปญฺหา ปฏิสีสติ ฯ

(๑๙) ปุน จปรํ มหาปณฺฑิโต ฯเปฯ สตฺถา อปริสุทฺธวจีสมาจาโร สมาโน ปริสุทฺธวจีสมาจารณฺหิ ปริสุทฺธา เม วจีสมาจารตา ปญฺญายติ อสงฺกิลิฏฺฐาตา จ ฯ ตเมนํ สาวกา ฯเปฯ ชานนฺติ อยมฺปิ โข ภวํ สตฺถา อปริสุทฺธวจีสมาจาโร

សៅហ្មង់ខ្លះ ។ ពួកសាវ័កតែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើននេះមានធម្មទេសនាមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានធម្មទេសនាបរិសុទ្ធខ្លះ ថាធម្មទេសនារបស់អញបរិសុទ្ធផ្សេងផ្ង ឥតមានសៅហ្មង់ខ្លះ ដូច្នេះ តែថាបើយើងច្រាប់(រឿងនោះ)ដល់ពួកគ្រហស្ថ គង់លោកមិនគាប់ចិត្ត កំរឿងណា មិនគាប់ចិត្តដល់លោក យើងនឹងសើរើរឿងលោកនោះដូចម្តេចបាន ព្រោះលោកកំពុងពប់អាន(យើង) ដោយចីវរ បិណ្ឌបាត សេនាសនៈនឹងគិលានប្បច្ចយភេសជ្ជបរិក្ខារ លោកនឹងឆ្លើតមួណា គង់លោកនឹងប្រាកដដោយកម្មនោះមិនខាន ។ ម្នាលមោគ្គល្លាន ពួកសាវ័កតែងរក្សាគ្រូបែបនេះ ដោយធម្មទេសនា ។ ឯគ្រូបែបនេះសោត តែងនឹកសង្ឃឹមនូវការរក្សាអំពីពួកសាវ័កដោយធម្មទេសនា ។

[๑๙] ម្នាលមោគ្គល្លាន ពាក្យដទៃនៅមានទៀត គ្រូពួកមួយក្នុងលោកនេះ មានវេយ្យាករណ៍មិនបរិសុទ្ធ តែប្តេជ្ញាថា អញមានវេយ្យាករណ៍បរិសុទ្ធខ្លះ ថា វេយ្យាករណ៍របស់អញបរិសុទ្ធផ្សេងផ្ង ឥតមានសៅហ្មង់ខ្លះ ។ ពួក សាវ័កតែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើន នេះមានវេយ្យាករណ៍មិន

សមាធោ បរិសុទ្ធវេយ្យាករណោ ម្ហីតិ បដិជានាតិ បរិសុ-
ទ្ធំ មេ វេយ្យាករណំ បរិយោទាតំ អសង្កិលិដ្ឋន្តិ ច មយំ
ចេវ ខោ បន តិហីនំ អាភេចេយ្យាម នាស្សុស្សុ មនាបំ
យំ ខោ បនស្សុ អមនាបំ កថន្តំ មយំ តេន សមុទាច-
វេយ្យាម សម្មន្នតិ ខោ បន ចីវរបិណ្ឌបាតសេនាសន-
លានប្បច្ចយភេសជ្ជបរិក្ខារេន យំ តុមោ ការិស្សតិ តុមោ
វ តេន បញ្ញាយិស្សតីតិ ។ ឥវរូបំ ខោ មោក្ខ្លាន សត្ថា
សាវកោ វេយ្យាករណោតោ វត្តព្ពំ ។ ឥវរូបោ ច បន
សត្ថា សាវកេហិ វេយ្យាករណោតោ វត្តុំ បង្ហាសីសតិ ។

(២០) បុន ចបរំ មោក្ខ្លាន ឥធេកច្ចោ សត្ថា
អបរិសុទ្ធញ្ញាណទស្សនោ សមាធោ បរិសុទ្ធញ្ញាណ-
ទស្សនោម្ហីតិ បដិជានាតិ បរិសុទ្ធំ មេ ញាណទស្សនំ
បរិយោទាតំ អសង្កិលិដ្ឋន្តិ ច ។ តមេនំ សាវកា ឯវំ
ជានន្តិ អយំ ខោ ភវំ សត្ថា អបរិសុទ្ធញ្ញាណទស្សនោ
សមាធោ បរិសុទ្ធញ្ញាណទស្សនោម្ហីតិ បដិជានាតិ ប-
រិសុទ្ធំ មេ ញាណទស្សនំ បរិយោទាតំ អសង្កិលិដ្ឋន្តិ ច

បរិសុទ្ធ តែប្តេជ្ញាថា អញមានវេយ្យាករណ៍បរិសុទ្ធខ្លះ ថាវេយ្យាករណ៍របស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ដូច្នេះ បើយើងត្រាប់ (រឿងនោះ) ដល់ពួកគ្រូហស្ត គង់លោកមិនគាប់ចិត្តទេ ក៏រឿងណាមិនគាប់ចិត្តដល់លោក យើងនឹងសើរើរឿងលោកនោះ ដូចម្តេចបាន ព្រោះលោកកំពុងកាប់អាន(យើង) ដោយចរិយបិណ្ឌបាត សេនាសនៈទិដ្ឋគិលានប្បច្ចយ-ភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណា គង់លោកនឹងប្រកាសដូរ្តែងព្រោះកម្មនោះមិនខាន ។ ម្នាលមោគ្គល្លាន ពួកសាវ័កតែងរក្សាគ្រូបែបនេះដោយវេយ្យាករណ៍ ។ ចំណែកខាងគ្រូនោះ តែងនឹកសង្ឃឹមនូវការរក្សាអំពីពួកសាវ័កដោយវេយ្យាករណ៍ ។

(๒๐) ម្នាលមោគ្គល្លាន ពាក្យដទៃនៅមានទៀត គ្រូពួកមួយក្នុងលោកនេះ មានញាណទស្សនៈមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានញាណទស្សនៈបរិសុទ្ធខ្លះ ថាញាណទស្សនៈរបស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ។ សាវ័កតែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើននេះមានញាណទស្សនៈមិនបរិសុទ្ធ តែប្តេជ្ញាថាអញមានញាណទស្សនៈបរិសុទ្ធខ្លះ ថាញាណទស្សនៈរបស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ដូច្នេះ

มยนฺ เจว เขา ตีหีนํ อาเกเจยฺยาย ฉาสฺสุ
มฺหาปนฺ ยนฺ เขา ปนสฺส อมฺหาปนฺ กเรยฺยุนฺ มยนฺ เตน
สมุฏฺฐาเปยฺยาม สมฺปฏิจฺฉติ เขา ปน จีวรปิณฺฑปาต-
เสนาสนคิลานปจฺจยเภสชฺชปริกฺขาเรน ยนฺ ตุเมฺห
กเรยฺยาถ ตุเมฺห ว เตน ปญฺญายิสฺสถาติ ฯ ฬาปิปนฺ
เขา เมาคฺคลฺลาน สตฺถารา สาวกา ญาณทสฺสนเต
รกฺขนฺติ ฯ ฬาปิเขา จ ปน สตฺถา สาวเกหิ ญาณ-
ทสฺสนเต รกฺขาปนฺ ปฏฺฐาสีสติ ฯ ตสฺมา เขา เมาคฺค-
ลฺลาน ปญฺห สตฺถาเร สญฺญา สาวฺหาปนฺ เลาเกสฺมิ ฯ

[๒๑] อหนฺ เขา ปน เมาคฺคลฺลาน ปริสุทฺธสีเล
สมาเน ปริสุทฺธสีเลมฺหิ ปติฏฺฐาเน ปริสุทฺธิ เม
สีลนฺ ปริเยสิตพฺพนฺ อสงฺกิลิฏฺฐนฺติ จ น จ ปน สาวเกา
สีลเต รกฺขนฺติ น จาหนฺ สาวเกหิ สีลเต รกฺขา
ปฏฺฐาสีสามิ ฯ ปริสุทฺธาชีเว สมาเน ฯเป ฯ ปริสุทฺธ-
ธมฺมเทสเน ฯเป ฯ ปริสุทฺธวิมุตฺติกาเร สมาเน
ฯเป ฯ ปริสุทฺธญาณทสฺสเน สมาเน ปริสุทฺธญา-
ณทสฺสเนมฺหิ ปติฏฺฐาเน ปริสุทฺธิ เม ญาณทสฺสนนฺ

បើយើងប្រាប់ (រឿងនោះ) ដល់ពួកគ្រហស្ថ តង់លោកមិនគាប់ចិត្តទេ
ក៏រឿងណាមិនគាប់ចិត្តដល់លោក យើងនឹងសើរើរឿងលោកនោះដូចម្តេច
បាន ព្រោះលោកកំពុងរាប់អាន(យើង) ដោយចីវរ បិណ្ឌបាត សេនា-
សនៈនឹងគិលានប្បច្ចយភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណា តង់លោកនឹង
ប្រាកដឡើងព្រោះកម្មនោះមិនមាន ។ ម្នាលមោគ្គល្លាន ពួកសាវ័កតែង
រក្សាគ្រូបៃបនេះដោយញាណទស្សនៈ ។ ក៏ឯគ្រូមានសភាពយ៉ាងនេះ
តែងនឹកសង្ឃឹមនូវការរក្សា អំពីពួកសាវ័កដោយញាណទស្សនៈ ។ ម្នាល
មោគ្គល្លាន គ្រូ ៥ ពួកនេះឯង តែងមានក្នុងលោក ។

(๒๑) ម្នាលមោគ្គល្លាន បំណែកខាងតថាគតជាបុគ្គលមានសីល
បរិសុទ្ធ ប្តេជ្ញាថា តថាគតមានសីលបរិសុទ្ធខ្លះ ថាសីលរបស់តថាគត
បរិសុទ្ធផ្សេងទៀត ឥតមានសៅហ្មងខ្លះ ។ ពួកសាវ័កមិនបានរក្សាតថាគត
ដោយសីលទេឬយ តថាគតសោតក៏មិនឧកសង្ឃឹមនូវការរក្សាអំពីពួកសា-
វ័កដោយសីលទេ ។ (តថាគត)មានអាជីវៈបរិសុទ្ធ ។បេ។ មានធម្មទេសនា
បរិសុទ្ធ ។ បេ ។ មានវេយ្យាករណ៍បរិសុទ្ធ ។ បេ ។ មានញាណទស្សនៈ
បរិសុទ្ធ ប្តេជ្ញាថា តថាគតមានញាណទស្សនៈបរិសុទ្ធខ្លះ ថាញាណទស្សនៈ

ปริเยาทาตํ อสณฺฐิเหยฺยนฺติ จ น จ มํ สาวกา ญาณ-
ทสฺสนเตวกฺขิตฺตนฺติ น จาหมฺปิ สาวเกหิ ญาณทสฺสน-
เตวกฺขิตฺโตติ ปฏิสีสาทีสุ ฯ

(๒๒) อถโข ภควา เตสญฺเญว ภิกฺขูนํ จิตฺตมญฺญาย
ตาวเทว ปาจีนวตา มิคทายา ยถาภิรนฺตนฺติ วิหา-
รโต นิกฺขมิตฺวา เยน ภณฺฑคามโก เตนุปสงฺกมิ อนุปุพฺพเน จา-
ริกญฺเญวาติ เยน ภณฺฑคามโก ตทวสริ ฯ ตตฺร สุทํ
ภควา ภณฺฑคาเม วิหรติ เวฬุวเน กลนฺทกนิวาเป ฯ

(๒๓) อถโข สมฺพหุลา ภิกฺขู เยน ภควา เตนุ-
ปสงฺกมึสุ อุปสงฺกมิตฺวา ภควนฺตํ อภิวาเทตฺวา ปจฺจตฺถนฺ
ติสีทึสุ ฯ ปจฺจตฺถนฺติสิตา โข เต ภิกฺขู ภควนฺตํ ปจ-
ตฺตเมวุปฺปตฺติยา ปุจฺฉึสุ อชาตสตฺตุ ภนฺเต วิทูภเว ปญฺจหิ
รถสเตหิ สายนฺหสมยนฺติ ตตฺถ ตตฺถ อุปฏฺฐานสาลาสุ
ธมฺมิกถาย นิสีทนฺติปิ ปญฺจ ฉณสมชฺชสตานิ ปจฺจุปฏฺฐิตานิ
โหนฺตีติ ตตฺถ ภิกฺขู อชาตสตฺตุ วิทูภเว ปญฺจหิ รถสเตหิ
สายนฺหสมยนฺติ อุปฏฺฐานสาลาสุ ธมฺมิกถาย นิสีทนฺติปิ ปญฺ
จ ฉณสมชฺชสตานิ ปจฺจุปฏฺฐิตานิ

របស់តថាគតបរិសុទ្ធផូរផង់ តតមានសៅហ្មង ខ្វះ សារ័កមិនរក្សាតថាគត ដោយញាណទស្សនៈទេ តថាគតសោតមិនតឹកសង្ឃឹមនូវការរក្សាអំពីពួកសារ័កដោយញាណទស្សនៈឡើយ ។

(๒๒) គ្រានោះ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងនគរកោសម្ពី គួរតាមពុទ្ធអធ្យាស្រ័យហើយ ស្តេចចៀសចាកនគរនោះ ត្រាច់ចៀសចាកតាមលំដាប់ ឆ្ពោះទៅនគរាជគ្រឹះ ។ បានឮថា ព្រះមានព្រះភាគគង់នៅក្នុងវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ទៀបនគរាជគ្រឹះ ។

(๒๓) លំដាប់នោះ កិក្ខុប្រើនរូបនាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចទើបអង្គុយក្នុងទីដ៏សមគួរ ។ កិក្ខុទាំងនោះ លុះអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលភាស្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន អជាតសត្តុកុមារតែងចៀសចេញដោយរថ ๕ រយ បម្រើទៅតួតាំងល្ងាចតាំងព្រឹក តាំងឲ្យអ្នកនាំសម្រាប់ យកសម្រាប់ ๕ រយថាស ទៅប្រគេន (ទៅតួផង)។ ព្រះអង្គទ្រង់ត្រាស់តបថា ម្នាលកិក្ខុតាំងឡាយ អ្នកកុំស្ទើចលាកសក្ការៈនឹងសេចក្តីសរសើរបស់ទៅតួឡើយ ម្នាលកិក្ខុតាំងឡាយ អជាតសត្តុកុមារដែលចៀសចេញដោយរថ ๕ រយ ទៀបម្រើទៅតួតាំងល្ងាចតាំងព្រឹក តាំងឲ្យអ្នកនាំសម្រាប់ យកសម្រាប់ ๕ រយថាស ទៅប្រគេន (ទៅតួ) ជារបណា

មហាឯយ្យ កិក្ខវ ខេវឧត្តសុ ចាដិកជ្ជ ភុសលេសុ
ជម្មេសុ ខោ ប្បុត្តិ សេយ្យថាបិ កិក្ខវេ ចណ្ឌាសុ ភុក្កុ-
រស្ស ជាសាយ បិត្តំ កិន្តេយ្យុំ ឯវំ ហិ សោ កិក្ខវេ
ភុក្កុភោ កិយ្យសោ មត្តាយ ចណ្ឌតរោ អស្ស ឯវមេវ
ខោ កិក្ខវេ យោភិក្ខុ ឥមំ ធម្មវិនយំ អជានន្តស្ស ភុមោ
បញ្ចមារ ថសតេមា សាយំ ចាតំ ឧបដ្ឋានំ គមិស្សតិ បញ្ច
ច ជាលិចាភសតានិ ភត្តាភិហារោ អភិហារិយ្យិស្សតិ
ហាឯយ្យ កិក្ខវេ ខេវឧត្តសុ ចាដិកជ្ជ ភុសលេសុ
ជម្មេសុ ខោ ប្បុត្តិ ។ អត្តាជាយ កិក្ខវេ ខេវឧត្តសុ
លាភសក្ការសិលោភោ ឧទបាធិ បភភាយ ខេវ-
ឧត្តសុ លាភសក្ការសិលោភោ ឧទបាធិ សេយ្យថាបិ
កិក្ខវេ ភទលី អត្តាជាយ ផលំ ខេតិ បភភាយ ផលំ
ខេតិ ឯវមេវ ខោ កិក្ខវេ អត្តាជាយ ខេវឧត្តសុ លាភ-
សក្ការសិលោភោ ឧទបាធិ បភភាយ ខេវឧត្តសុ
លាភសក្ការសិលោភោ ឧទបាធិ សេយ្យថាបិ កិក្ខវេ
វេឡុ អត្តាជាយ ផលំ ខេតិ បភភាយ ផលំ ខេតិ

ម្នាលភិក្ខុទាំងឡាយ សេចក្តីសាបសូន្យមុខជានឹងតែងមានដល់ទេវទត្ត (ដរាបនោះ) មិនខាន ឯការបំរើនក្នុងកុសលធម៌មិនមានឡើយ ម្នាលភិក្ខុទាំងឡាយ ដូចគេច្រចាប់ទឹកប្រមាត់ (ត្រីឆ្លាមឃ្មុំ) ជាក់ក្តួនប្រមុះឆ្អែកាច ឆ្អែនោះតែងតែកាចឡើងជាងដើម យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ក៏ដូចជាអជាតសត្តុកុមារទៅដោយរថ ៥ រយ បម្រើទេវទត្តទាំងល្ងាចទាំងព្រឹក ទាំងឲ្យអ្នកនាំសម្រាប់ យកសម្រាប់ ៥ រយថាសទៅប្រគេន (ទេវទត្ត) ដរាបណា សេចក្តីសាបសូន្យមុខជានឹងកើតមានដល់ទេវទត្ត (ដរាបនោះ) ពុំខាន ការបំរើនក្នុងកុសលធម៌ មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនឹងសេចក្តីសរសើរកើតឡើងហើយដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈនឹងសេចក្តីសរសើរកើតឡើងហើយដល់ទេវទត្ត ដើម្បីសេចក្តីវិនាស ម្នាលភិក្ខុទាំងឡាយ ដើមចេកចេញផ្លែ ដើម្បីសម្លាប់ដើម ចេញផ្លែ ដើម្បីវិនាស យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនឹងសេចក្តីសរសើរកើតឡើងហើយដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈនឹងសេចក្តីសរសើរ កើតឡើងហើយដល់ទេវទត្ត ដើម្បីសេចក្តីវិនាស ក៏ដូច្នោះដែរ ម្នាលភិក្ខុទាំងឡាយ ឫស្សីចេញផ្លែ ដើម្បីសម្លាប់ដើម ចេញផ្លែ ដើម្បីសេចក្តីវិនាសយ៉ាងណា

ฝ่ายเมรา ข้า ภิกษุเห็น อัตภาพ ของเทวดา ชื่อ สักกา-
ระสิโลกา ของพระขีณาสพ ชื่อ ปกกภาย ของเทวดา ชื่อ สัก-
การะสิโลกา ของพระขีณาสพ ชื่อ เสยยถาปิ ภิกษุเห็น
อัตภาพ ๘ ลำ เตียง ๘ ลำ ฝ่ายเมรา ข้า ภิกษุเห็น อัตภาพ
ของเทวดา ชื่อ สักการะสิโลกา ของพระขีณาสพ ชื่อ ปกกภาย
ของเทวดา ชื่อ สักการะสิโลกา ของพระขีณาสพ ชื่อ เสยยถาปิ ภิกษุ
อัตภาพ ๘ ลำ เตียง ๘ ลำ ฝ่ายเมรา ข้า ภิกษุเห็น อัตภาพ
ของเทวดา ชื่อ สักการะสิโลกา ของพระขีณาสพ ชื่อ ปกกภาย ของเทวดา ชื่อ สัก-
การะสิโลกา ของพระขีณาสพ ชื่อ เสยยถาปิ ฯ

(๒๔) ๘ลำ เห็น กองไฟ ใหญ่
๘ลำ เตียง ๘ลำ นอน
สักการะ กาปุริสะ ใหญ่
ตรัส อสุภะ ยถา ฯ

ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនឹងសេចក្តីសរសើរ កើតឡើងហើយ ដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈនឹងសេចក្តីសរសើរកើតឡើង ហើយដល់ទេវទត្ត ដើម្បីបំផ្លាញខ្លួន កំដួងនេះដែរ ម្នាលភិក្ខុទាំងឡាយ ដូចដើមបុរស ចេញផ្លែ ដើម្បីសម្លាប់ដើម ចេញផ្លែ ដើម្បីសេចក្តីវិនាស យ៉ាងណា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនឹងសេចក្តីសរសើរកើតឡើងដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈនឹងសេចក្តីសរសើរកើតឡើងដល់ទេវទត្ត ដើម្បីបំផ្លាញខ្លួន កំដួងនេះដែរ ម្នាលភិក្ខុទាំងឡាយ ដូចមេសេះអស្សតរ មានផ្លែដើម្បីសម្លាប់ខ្លួន មានផ្លែ ដើម្បីវិនាសខ្លួន យ៉ាងណា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនឹងសេចក្តីសរសើរកើតឡើងដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈនឹងសេចក្តីសរសើរកើតឡើងដល់ទេវទត្តដើម្បីបំផ្លាញខ្លួន កំដួងនេះដែរ ។

[๒๔] ផ្លែចេកតែងសម្លាប់ដើមចេក ផ្លែឫស្សីតែងសម្លាប់ដើមឫស្សី ផ្លែបុរសតែងសម្លាប់ដើមបុរស សក្ការៈតែងសម្លាប់បុរសអាក្រក់ ដូចជាគភិតែងសម្លាប់មេសេះអស្សតរ ។

ចប់ ភាណវារៈ ទី ๑ ។

[๒๙] តេន ខោ បន សមយេន ភគវា អហោគង្គា-
យ បរិសាយ បរិវុតោ ឆឌ្ឍេ ទេវេ សន្តេ និសិន្នោ
ហោតិ សរភង្គាយ[๑]។ អថ ខោ ទេវោ ទេវធម្មោ ទុដ្ឋា យោស-
ញ្ច ឱកាសំ ទុគ្គតមនុស្សំ ភរិត្វា យេន ភគវា តេនុប-
សង្កមិ បញ្ចាភេត្វា ភគវន្តំ ឯតទវោច ឯណ្ឌោ ទានិ ភន្តេ
ភគវា វុដ្ឋាសិ មហាលុទ្ទោ អទ្ធុគតោ វយោអនុប្បត្តោ
អបេ្បសក្ខោ ទានិ ភន្តេ ភគវា ឯកច្ចមេ្ហ សុខវិហារមនុ-
យុត្តោ វិហរតុ មម កិក្ខុសង្ឃំ និស្សជ្ជតុ អហំ កិក្ខុ-
សង្ឃំ បរិហរិស្សាមីតិ ។ អលំ ទេវធម្ម អា តេ រុច្ចិ
កិក្ខុសង្ឃំ បរិហរាតុន្តិ ។ ទុតិយម្បិ ខោ ។ បេ ។ ត-
តិយម្បិ ខោ ទេវធម្មោ ភគវន្តំ ឯតទវោច ឯណ្ឌោ ទានិ
ភន្តេ ភគវា វុដ្ឋាសិ មហាលុទ្ទោ អទ្ធុគតោ វយោ-
អនុប្បត្តោ អបេ្បសក្ខោ ទានិ ភន្តេ ភគវា ឯកច្ចមេ្ហ
វិហារមនុយុត្តោ វិហរតុ មម កិក្ខុសង្ឃំ និស្សជ្ជតុ

---

๑ ឥតោ បរំ ឆេត្តុកេស បរិសាយាតិ ចាហោ ទិស្សតិ ។

[២៥] សម័យនោះឯង ព្រះមានព្រះភាគមានបរិសទ្យច្រើន ព្រមទាំងស្តេចចោមរោមស្តាប់ធម្ម ព្រះអង្គកំពុងគង់សំដែងធម៌ ។ គ្រានោះ ទេវទត្តក្រោកចាកទីអង្គុយ ធ្វើចីវរឆៀងស្មាម្ខាង ប្រណម្យអញ្ជលីឆ្ពោះទៅរកព្រះ មានព្រះភាគ ហើយក្រាបបង្គំទូលភាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ព្រះជរា មានព្រះដន្ចបម្រើនហើយ ចាស់ព្រះអង្គហើយ ទ្រង់ព្រះដន្ចយូរឆ្នាំមកហើយ មានព្រះដន្ចស្រុលចូលមកក្នុងបច្ចិមវ័យហើយ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ សូមព្រះមានព្រះភាគកុំទ្រូលាយពេក សូមសម្រាកព្រះអង្គឲ្យបានសុខស្រួលក្នុងបច្ចុប្បន្ននេះកុះ សូមព្រះអង្គប្រគល់ភិក្ខុសង្ឃឲ្យមកខ្ញុំព្រះអង្គខ្ញុំព្រះអង្គនឹងទទួលគ្រប់គ្រងភិក្ខុសង្ឃ ។ ព្រះអង្គទ្រង់ត្រាស់តបថា ម្នាលទេវទត្ត ណ្ហើយអ្នកកុំពេញចិត្តនឹងការគ្រប់គ្រងភិក្ខុសង្ឃឡើយ ។ ទេវទត្តបានក្រាបទូលពាក្យនេះនឹងព្រះមានព្រះភាគអស់វារៈពីរដងផង ។ បេ ។ អស់វារៈបីដងផងថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ព្រះអង្គទ្រង់ព្រះជរា មានព្រះដន្ចបម្រើនហើយ ចាស់ព្រះអង្គហើយ ទ្រង់ព្រះដន្ចយូរឆ្នាំមកហើយ មានព្រះដន្ចស្រុលក្នុងបច្ចិមវ័យហើយ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ សូមព្រះមានព្រះភាគកុំទ្រូលាយពេក សូមសម្រាកព្រះអង្គឲ្យបានសុខស្រួលក្នុងបច្ចុប្បន្ននេះកុះ សូមព្រះអង្គប្រគល់ភិក្ខុសង្ឃឲ្យមកខ្ញុំព្រះអង្គ

អហំ តំ ក្ខុសង្ឃំ បរិហារំ ទស្សាមីតិ ។ សារីបុត្តមោគ្គល្លា-
នាំ ទោ អហំ ទេវទត្ត តំ ក្ខុសង្ឃំ ន ទស្សាមីតិ យំ តេ
តីវ បន តុយ្ហំ ឆន្ទោ រុចិ ខេត្តាសកាសកាតិ[1] ។ អថ ខោ
ទេវទត្តោ សកាយ បរិសាយ ខេត្តាសកាយ បរិសាយ ខេត្តា-
សកាតេន[2] អបសាទេតិ សារីបុត្តមោគ្គល្លានេវ ទុក្ខាំ-
សតីតិ កុបិតោ អនត្តមនោ ភគវន្តំ អភិវាទេត្វា
បទក្ខិណំ កត្វា បក្កាមិ ។ អថ ខ្វេ ចរហិ[3] ទេវ-
ទត្តស្ស ភគវតិ បឋមោ អាឃាតោ អបោសិ ។

(២៦) អថ ខោ ភគវា តំ ក្ខុ អាមន្តេសិ តេនហិ
តំ ក្ខវោ សង្ឃោ ទេវទត្តស្ស ភរដ្ឋមោ បតាសនីយ-
កម្មំ ករោតុ បុព្វេ ទេវទត្តស្ស អញ្ញោ បកតិ អបោសិ
ឥទានិ អញ្ញោ បកតិ យំ ទេវទត្តោ ករេយ្យ តាយេន
វាចាយ ន តេន ពុទ្ធោ វ ធម្មោ វ សង្ឃោ វ
ទដ្ឋព្ពោ ទេវទត្តោ វ តេន ទដ្ឋព្ពោតិ ។ ឯវញ្ហ បន
តំ ក្ខវោ ភាគតព្ពំ ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ

---

๑ ឆ. ម. ខេឡាបកសុត្តតិ ។ ๒ ឆ. ម. ខេឡកឡាវិទេន ។ ๓ ឆ. តរហិ ។

ខ្ញុំព្រះអង្គនឹងគ្រប់គ្រងកិក្ខុសង្ឃ ។ ព្រះអង្គទ្រង់ត្រាស់តបថា ម្នាលទេវទត្ត អម្បាលយ៉ាងសារីបុត្តនឹងមោគ្គល្លាន ម្តេច តថាគតមិនប្រគល់កិក្ខុសង្ឃឲ្យ ចំណង់បើអ្នកជាមនុស្សជ្រូជាតិអាក្រក់ ជាមនុស្សប្រភេទគូថ-ប្បច្ច័យដែលកើតអំពីអនេសនៈដូចជាដុំទឹកមាត់ តថាគតនឹងប្រគល់ឲ្យដូចម្តេចបាន ។ លំដាប់នោះ ទេវទត្តមានសេចក្តីក្រោធ អាក់អន់ចិត្តថា ព្រះមានព្រះភាគ ធ្វើអញឲ្យអាប់មុខក្នុងកណ្តាលបរិសទ្យព្រមទាំងស្តេចដោយពាក្យថា(ទេវទត្តនេះ)បរិភោគចតុប្បច្ច័យដែលកើតអំពីអនេសនៈដូចជាដុំទឹកមាត់ ហើយបែរទៅលើកតំកើងសារីបុត្តនឹងមោគ្គល្លានវិញ ហើយក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ ។ នេះជាគំនុំដម្បង របស់ទេវទត្តចំពោះព្រះមានព្រះភាគ ។

(៦៦) លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅកិក្ខុទាំងឡាយមកថា ម្នាលកិក្ខុទាំងឡាយ បើដូច្នោះ ត្រូវសង្ឃធ្វើបាសនីយកម្មដល់ទេវទត្តកន្លងគរោដគ្រឹះ (ដ្បិត)កាលពីដើមទេវទត្តមានប្រក្រតីផ្សេងៗឥឡូវនេះ មានប្រក្រតីផ្សេង ទេវទត្តធ្វើអំពើណាដោយកាយ វាចា អំពើនោះនាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្តត្រូវគេឃើញដោយកម្មនោះតែម្យ៉ាង ។ ម្នាលកិក្ខុទាំងឡាយ បាសនីយ-កម្ម សង្ឃគប្បីធ្វើយ៉ាងនេះ។ គប្បីឲ្យកិក្ខុដែលឈ្មោះប្រតិពលប្រកាសសង្ឃ

ញ្ញោបេតញ្ច សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ នេវទន្តស្ស ភិក្ខុកម្មំ បកាសនីយកម្មំ ករេយ្យ បុព្ពេ នេវទត្តស្ស អញ្ញា បកតិ អហោសិ ឥទានិ អញ្ញា បកតិ យំ នេវទត្តោ ករេយ្យ ការាយេន ឋបាយ ន តេន ពុទ្ធោ ឋ ធម្មោ ឋ សង្ឃោ ឋ ទដ្ឋព្ពោ នេវទត្តោ វ តេន ទដ្ឋព្ពោតិ ។ បសាញ្ញតិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ នេវទត្តស្ស ភិក្ខុកម្មំ បកាសនីយកម្មំ ករោតិ បុព្ពេ នេវទត្តស្ស អញ្ញា បកតិ អហោសិ ឥទានិ អញ្ញា បកតិ យំ នេវទត្តោ ករេយ្យ ការាយេន ឋបាយ ន តេន ពុទ្ធោ ឋ ធម្មោ ឋ សង្ឃោ ឋ ទដ្ឋព្ពោ នេវទត្តោ វ តេន ទដ្ឋព្ពោតិ ។ យស្សាយស្មតោ ខមតិ នេវទត្តស្ស ភិក្ខុកម្មំ បកាសនីយកម្មស្ស ករណំ បុព្ពេ នេវទត្តស្ស អញ្ញា បកតិ អហោសិ ឥទានិ អញ្ញា បកតិ យំ នេវទត្តោ ករេយ្យ ការាយេន ឋបាយ ន តេន ពុទ្ធោ ឋ ធម្មោ ឋ សង្ឃោ ឋ ទដ្ឋព្ពោ នេវទត្តោ វ តេន ទដ្ឋព្ពោតិ សោ តុណ្ហស្ស យស្ស ន ក្ខមតិ

ឲ្យដើរថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីធ្វើបាសនីយកម្មដល់ទេវទត្តក្នុងនគរាជគ្រឹះ (ដូរ្តិ)ពីដើមទេវទត្តមានប្រក្រតីផ្សេង ឥឡូវនេះមានប្រក្រតីផ្សេង ទេវទត្តធ្វើអំពើណាដោយកាយវាចា អំពើនោះនាំគាត់ឲ្យលែងជ្រាបឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្តត្រូវគេឃើញដោយកម្មនោះតែម្យ៉ាង ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃធ្វើបាសនីយកម្មដល់ទេវទត្តក្នុងនគរាជគ្រឹះ (ដូរ្តិ)ពីដើមទេវទត្តមានប្រក្រតីផ្សេង ឥឡូវនេះ មានប្រក្រតីផ្សេង ទេវទត្តធ្វើអំពើណាដោយកាយវាចា អំពើនោះនាំគាត់ឲ្យលែងជ្រាបឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្តត្រូវគេឃើញដោយកម្មនោះតែម្យ៉ាង ។ ការធ្វើបាសនីយកម្មដល់ទេវទត្តក្នុងនគរាជគ្រឹះថា កាលពីដើមទេវទត្តមានប្រក្រតីផ្សេង ឥឡូវនេះមានប្រក្រតីផ្សេង ទេវទត្តធ្វើអំពើណាដោយកាយវាចា អំពើនោះនាំគាត់ឲ្យលែងជ្រាបឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្តត្រូវគេឃើញដោយកម្មនោះតែម្យ៉ាង ដូច្នេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា

សោ ភាសេយ្យ ។ តតំ សង្ឃេន ទេវទត្តស្ស ភេទ-
ហេ បតិ្ដាសនីយតិ្ដំ បុព្ពេ ទេវទត្តស្ស អញ្ញា បតិ្ដ
អហេសិ ឥទានិ អញ្ញា បតិ្ដតិ យំ ទេវទត្តោ តរេយ្យ
តាយេន ភាថាយេ ន តេន ពុទ្ធោ ភ ធម្មោ ភ សង្ឃោ
ភ ទដ្ឋព្ពោ ទេវទត្តោ វ តេន ទដ្ឋព្ពោតិ ១បតិ សង្ឃស្ស
តស្មា ភុល្លោ ។ ឃវមេតំ ជានយោបីតិ ។

[២៧] អថខោ ភគវា អាយស្មន្តំ សារីបុត្តំ អា-
មន្តេសិ តេនហិ ត្វំ សារីបុត្ត ទេវទត្តំ ភេទហេ
បតិ្ដាសេហីតិ ។ បុព្ពេ មយា ភន្តេ ទេវទត្តស្ស
ភេទហេ វណ្ណោ ភាសិតោ មហិទ្ធិកោ តោធិបុត្តោ
មហានុភាវោ តោធិបុត្តោតិ តថាហំ ភន្តេ ទេវ-
ទត្តំ ភេទហេ បតិ្ដាសេមីតិ ។ ឯតុ ភយា សារីបុត្ត
ភូតោយេវ ទេវទត្តស្ស ភេទហេ វណ្ណោ ភាសិតោ
មហិទ្ធិកោ តោធិបុត្តោ មហានុភាវោ តោធិបុត្តោតិ ។

លោកដ៏មានអាយុអង្គនោះគប្បីឆ្លើយឡើង ។ សង្ឃបានធ្វើបកាសនយកម្ម ដល់ទេវទត្តក្នុងនគរោជគ្រឹះថា ពីដើមទេវទត្តមានប្រក្រតីផ្សេង ឥឡូវនេះ មានប្រក្រតីផ្សេង ទេវទត្តធ្វើអំពើណាដោយកាយវាចា អំពើនោះនាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្ត ត្រូវគេឃើញដោយកម្មនោះតែម្យ៉ាង៑ ការធ្វើបកាសនយកម្មនោះ គួរដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្មើ ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះដោយការស្មើមយ៉ាងនេះ ។

(៦៧) លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះសារីបុត្តដ៏មានអាយុមកថា ម្នាលសារីបុត្ត បើដូច្នោះ ចូរអ្នកប្រកាស (ទោស) ទេវទត្តក្នុងនគរោជគ្រឹះ ។ ព្រះសារីបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន កាលពីមុនខ្ញុំព្រះអង្គបានប្រកាសគុណទេវទត្តក្នុងនគរោជ-គ្រឹះថា ទេវទត្តជាគោធិបុត្តមានឫទ្ធិច្រើន ជាគោធិបុត្តមានអានុភាពច្រើន បពិត្រព្រះអង្គដ៏ចំរើន (ឥឡូវនេះ) ខ្ញុំព្រះអង្គនឹងប្រកាស (ទោស) ទេវទត្តដូចម្តេចបាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលសារីបុត្ត អ្នកបានប្រកាសគុណពិតរបស់ទេវទត្តក្នុងនគរោជគ្រឹះថា ទេវទត្តជាគោធិបុត្ត មានឫទ្ធិច្រើន ជាគោធិបុត្តមានអានុភាពច្រើន ដូច្នោះហើយឬ ។

ฬาโ ภนฺเตติ ฯ ฬาโมฆา โข ตฺวํ สาริปุตฺต ภูตปุพฺพ
โนวาทตฺถํ ภควตาหโม ปกาสิตาติ ฯ ฬาโ ภนฺเตติ โข
อายสฺมา สาริปุตฺโต ภควโต ปจฺจสฺโสสิ ฯ

[๒๘] อถโข ภควา ภิกฺขู อามนฺเตสิ เตนหิ
ภิกฺขเว สงฺฆา สาริปุตฺตํ สมฺมนฺตถ โนวาทตฺถํ ภควตาหโม
ปกาสิตุ ปุพฺเพ โนวาทกสฺส อญฺญา ปกาติ อโหสิ
ตถาติ อญฺญา ปกาติ ยถา โนวาทกา กาเยน
วาจาย น เตน ตุณฺหี ว ฉมฺหา ว สงฺฆา ว นฺหายนฺติ
โนวาทกา เตน นฺหายนฺติ ฯ ตาวญฺจ ปน ภิกฺขเว
สมฺมนฺติตพฺพา ฯ ปถมา สาริปุตฺตา ยาจิตพฺพา ฯ ยา-
จิตฺวา ตฺยาสฺส ภิกฺขู ปฏิพลา สงฺฆา ญาเปตพฺพา
สุณาตุ เม ภนฺเต สงฺฆา ยทิ สพฺพสฺส ปตฺตกลฺลา
สงฺฆา อายสฺมนฺตา สาริปุตฺตา สมฺมนฺเยยฺย โนวาทตฺถา ภควา-
ตาหโม ปกาสิตุ ปุพฺเพ โนวาทกสฺส อญฺญา ปกาติ อ-
โหสิ ตถาติ อญฺญา ปกาติ ยถา โนวาทกา กาเยน
วาจาย น เตน ตุณฺหี ว ฉมฺหา ว สงฺฆา

ព្រះសារីបុត្តក្រាបបង្គំទូលថា ភុំណាព្រះអង្គ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលសារីបុត្ត ចូរអ្នកប្រកាស (ទោស) ទៅទត្តឲ្យពិតយ៉ាងនោះចុះ ។ ព្រះសារីបុត្តដ៏មានអាយុក្រាបបង្គំទូលថា ភុំណាព្រះអង្គ ។

(៤៨) គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរសន្ឋតសារីបុត្ត ដើម្បីឲ្យប្រកាស (ទោស) ទៅទត្តក្នុងនគរោជគ្រឹះថា ពីដើមទៅទត្តមានប្រក្រតីផ្សេង ឥឡូវនេះ មានប្រក្រតីផ្សេង ទៅទត្តធ្លាប់អំពើណាដោយកាយវាចា អំពើនោះនាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទៅទត្តត្រូវគេឃើញដោយអំពើនោះតែម្យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសន្ឋតយ៉ាងនេះ ។ សង្ឃត្រូវសូមសារីបុត្តជាដំបូងសិន ។ លុះសូមរួចហើយ ត្រូវឲ្យភិក្ខុជាអ្នកធ្វាសប្រតិពលប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើតម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីសន្ឋតព្រះសារីបុត្តដ៏មានអាយុ ដើម្បីឲ្យប្រកាស (ទោស) ទៅទត្តក្នុងនគរោជគ្រឹះថា (ដំណែ) ពីដើមទៅទត្តមានប្រក្រតីផ្សេង ឥឡូវនេះមានប្រក្រតីផ្សេង ទៅទត្តធ្លាប់អំពើណាដោយកាយវាចា អំពើនោះនាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ

ឯ ឧដ្ឋញ្ចេ ទេវឧត្តោ វ តេន ឧដ្ឋញ្ចេ ។ ឯសា ញត្តិ ។ សុណាតុ មេ អន្តេ សង្ឃោ សង្ឃោ អាយស្មន្តំ សារី-បុត្តំ សម្មន្តតិ ទេវឧត្តំ ភជតហោ បតិសេតុំ បុព្ពេ ទេវឧត្តស្ស អញ្ញា បតិតិ អហោសិ ឥទានិ អញ្ញា បតិតិ យំ ទេវឧត្តោ តិរេយ្យ តិរេយន ឯថាយ ន តេន ពុទ្ធោ ឯ ធម្មោ ឯ សង្ឃោ ឯ ឧដ្ឋញ្ចេ ទេវឧត្តោ វ តេន ឧដ្ឋញ្ចេ-តំ ។ យស្សាយស្មតោ ខមតិ អាយស្មតោ សារីបុត្តស្ស សម្មតិ ទេវឧត្តំ ភជតហោ បតិសេតុំ បុព្ពេ ទេវឧត្តស្ស អញ្ញា បតិតិ អហោសិ ឥទានិ អញ្ញា បតិតិ យំ ទេវ-ឧត្តោ តិរេយ្យ តិរេយន ឯថាយ ន តេន ពុទ្ធោ ឯ ធម្មោ ឯ សង្ឃោ ឯ ឧដ្ឋញ្ចេ ទេវឧត្តោ វ តេន ឧដ្ឋញ្ចេតំ សោ តុណ្ហស្ស យស្ស ឧក្កមតិ សោ តិរេយ្យ ។ សម្មតោ សង្ឃេន អាយស្មា សារីបុត្តោ ទេវឧត្តំ ភជតហោ បតិ-សេតុំ បុព្ពេ ទេវឧត្តស្ស អញ្ញា បតិតិ អហោសិ ឥទានិ អញ្ញា បតិតិ យំ ទេវឧត្តោ តិរេយ្យ តិរេយន ឯថាយ

ទេវទត្តត្រូវគេយើញដោយអំពើនោះតែម្យ៉ាង ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតព្រះសារីបុត្តដ៏មានអាយុ ឲ្យជាអ្នកប្រកាស (ទោស) ទេវទត្តក្នុងនគរោជគ្រឹះថា កាលពីដើមទេវទត្តមានប្រក្រតីផ្សេង ឥឡូវនេះមានប្រក្រតីផ្សេង ទេវទត្តធ្វើអំពើណាដោយកាយវាចា អំពើនោះនាំគាត់ឲ្យលែងបានយើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្តត្រូវគេយើញដោយអំពើនោះតែម្យ៉ាង ។ ការសន្មតព្រះសារីបុត្តដ៏មានអាយុឲ្យជាអ្នកប្រកាស (ទោស) ទេវទត្តក្នុងនគរោជគ្រឹះថា កាលពីដើមទេវទត្តមានប្រក្រតីផ្សេង ឥឡូវនេះមានប្រក្រតីផ្សេង ទេវទត្តធ្វើអំពើណាដោយកាយវាចា អំពើនោះនាំគាត់ឲ្យលែងបានយើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្តត្រូវគេយើញដោយអំពើនោះតែម្យ៉ាង ដូច្នេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីនិយាយទ្បើង ។ សង្ឃបានសន្មតព្រះសារីបុត្តដ៏មានអាយុ ឲ្យជាអ្នកប្រកាស (ទោស) ទេវទត្តក្នុងនគរោជគ្រឹះថា ពីដើមទេវទត្តមានប្រក្រតីផ្សេង ឥឡូវនេះមានប្រក្រតីផ្សេង ទេវទត្តធ្វើអំពើណាដោយកាយវាចា

น เตน ภุตฺตา ภ ฒมฺหา ภ สเงฺฆ ภ ฒฏฺเฐ เวฬุทานฺเต
